# លោកនីតិបករណ៍

ព្រះអុក-ជា

វជិរញ្ញាណាភយវង្ស

ទិប្បតុ ជិនសាសនំ

រាជធានីចតុមុខភ្នំពេញ

អំណោយពីលោក ខៀវ ឃុនសិរីវង្ស ដល់ក្រុមការងារ
សម្រាប់ដំកល់ទុកក្នុង eLibrary of Cambodia

# លោកនិតិបករណ៍

ព្រះ អ៊ុក-ជា
វជិរញ្ញាណាភយវង្ស
អតីតក្រុមជំនុំព្រះត្រៃបិដក ក្រសួងពុទ្ធសាសនបណ្ឌិត្យ
ក្រុងភ្នំពេញ
រៀបរៀងតាមរបៀប
លោកអ្នកឧកញ៉ាសុត្តន្តប្រីជាឥន្ទ

បោះពុម្ពលើកទីពីរ
ព.ស. ២៤៩៦ គ.ស. ១៩៥៣
ក្រុងភ្នំពេញ

# លោកនីតិបករណ

នមត្ថុរតនត្តយស្ស

លោកនីតឹ បវក្ខាមិ នានាសត្ថសមុទ្ធតំ
មាគធេនេវ សង្ខេបំ[១] វន្ទិត្វា រតនត្តយំ ។

នីតិ លោកេ បុរិសស្ស សារោ
មាតាបិតា អាចរិយោ ច មិត្តោ
តស្មា ហិ នីតឹ បុរិសោ វិជញ្ញា
ញាណី មហា ហោតិ ពហុស្សុតោ ច ។

(ប្រែថា) ខ្ញុំព្រះករុណាទំនុកញ្ញា សុត្តន្តប្រែជាឥន្ទុបណ្ឌិត
សូមប្រែគម្ពីរលោកនីតិ វិចិត្រដោយពចន៍ពាក្យកាព្យ ។
តាមពាក្យបុរាណាចារ្យចែង លោកតែងឆន្ទបាទបទបទ្យ
ប្រាំបី ១ គូរគូក បួនបាទមួយគាថាដោយនិយម ។
សេចក្ដីថាខ្ញុំព្រះករុណា វន្ទិត្វាទនកាយថ្វាយបង្គំ
ប្រជុំរត្នត្រ័យថ្លៃឧត្ដម ស្រេចខ្ញុំសូមពោលក្បួនលោកនីតិ ។

១- បោរាណពោត្ថកេ "សង្ខេបេត, ពិ វិស្សុតំ" ។

គឺអ្នកប្រាជ្ញលោកនាំចាកគម្ពីរ ផ្សេងៗ តាមចំណែកប្រសិទ្ធិ
ជាពាក្យមគធបាលីពិត វិចិត្រសំរេចបែបបទ្ទី ១ ។
នីតិសាស្ត្រនេះជាខ្លឹមសារ ទុកជាករពារដែនប្រុសស្រី
ជាម៉ែជាឪមិត្រភក្តិ បុរសក្នុងលោកក៏គួរស្វាធ្យាយ ។
តស្មាហេតុនោះប្រុសឯណា កបញ្ញាណបញ្ញាអភិប្រាយ
បានរៀនលោកនីតិទុកក្នុងកាយ ប្រុសនោះខ្ពុរខ្ចាយនាមបណ្ឌិត ។
កបញ្ញាណបញ្ញាក្លាហេតុ ជាពហុស្សុតប្រាជ្ញព្រោកពិត
គតិលោកគតិធម៌លោកវិចិត្រ មានក្នុងលោកនីតិច្បាប់នេះហោង ។

ចប់ទម្ស្ការបរិបូណ៌

## បណ្ឌិតកណ្ឌទី ១

(១) អលសស្ស កុតោ សិប្បំ អសិប្បស្ស កុតោ ធនំ
អធនស្ស កុតោ មិត្តំ អមិត្តស្ស កុតោ សុខំ
អសុខស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតា សិរី(១)ៗ

១ សិល្បសាស្ត្រមានពីណាដល់អ្នកខ្ជិល ទ្រព្យធនបានពីណាអ្នកឥតសិល្ប មិត្រឯណាមានអ្នកបន្ទូលឥតធនធាន សុខឯណាមានដល់

១– លោកណាតោត្ថកេ “ មិត្តំ ” ត្តិ ខាយ៉ះ ។

អ្នកប្រាសម៉ែត្រ បុត្រាទ័ឯណា មានដល់អ្នកឥតកក្រ្ត សិរីមោក្ខយោគកែ
ព្រះនិព្វាន មានពីណាដល់អ្នកគ្មានបុណ្យកុសាន៍ ។

ដ ជាតិកំពីល ផឹកស្រាស្រីឯណា ហាន ផឹកស្រាស្រីខាតទ្រព្យសម្បត្តិ
អន្តរធាន សម្បត្តិគ្មានញាតិមិត្រឥតមកវល់ ឥតមិត្រត្រេកមេត្រី
ក៏សុខគ្មាន ឥតសុខសាន្តគ្មានបុណ្យគ្មានកុសល ឥតបុណ្យយោគសិរី-
មោក្ខទៅមិនដល់ ចុះក្នុងកលកាមភពផុបជាប់ហោង ។

(២) សិប្បសមំ ធនំ នត្ថិ សិប្បំ ចោរា ន គណ្ហន្តិ
ឥធ លោកេ សិប្បំ មិត្តំ បរលោកេ សុខាវហំ ។

៧ មានទ្រព្យមិនស្មើបានវិជ្ជា វិជ្ជាចោរលួចយកមិនបាន
វិជ្ជាទុកជាមិត្រសន្តាន ក្បួនក្នុងឥធលោកយោគបរលោក ។

(៣) អប្បំ ឆាតិមញ្ញេយ្យ បត្តេសុ តំ និដ្ឋាបេយ្យ
វិម្មុក្ខទកពិន្ទុ[១] បិវេន បរិបូរតិ ។

១ បោរាណបោត្ថកេ "វម្មិកេ ឧទកពិន្ទុ,តិ បាឋោ អាគតោ ។

៧- កុំមើលងាយថាបញ្ញាតិច   រៀនទៅក្រែងក្លាយមិនបំរើន
សូម្បីមួយបញ្ញាបើច្រើន   យូរទៅគង់នឹងពេញហឫទ័យ ។
ដូចក្អមដំកល់លើដំបូក   ភ្លៀងធ្លាក់ៗតាមចិន្ត្រ័យ
ដំណក់តក់ៗតែរាល់ថ្ងៃ   អស់ស្ម័យយូរទៅគង់ពេញបាន ។

(៤) ខុទ្ទាតិនាតិមញ្ញេយ្យ   វិជ្ជា សិប្បមថវា(១)
ឯកំ បិ បរិយោទាតំ   ជីវិតកប្បការណំ ។

៧ កុំមើលងាយមនុស្សសិល្បសាស្ត្រា   គិតថាតិចតួចក្រែងមិនស្រេច
វិជ្ជាមួយមែនបើមិនភ្លេច   គង់នឹងសម្រេចប្រយោជន៍បាន ។
ទោះមួយទោះពីរឲ្យតែស្ទាត់   ប្រែកប្រែកជម្រកចំណាន
ជាហេតុចិញ្ចឹមជីវិតបាន   សន្តានជួលពឹងពុំនឹងអើយ ។

(៥) សេលេសេលេ ន មណិកំ   គជេគជេ ន មុត្តកំ(២)
វនេ វនេ ន ចន្ទនំ   ឋានេ ឋានេ ន បណ្ឌិតំ ។

៨ កែវមណីមិនមានសព្វថ្មភ្នំ   គជៈមុក្តមិនមានសព្វដំរីជ័យ
ជាតិខ្លឹមចន្ទន៍មិនមានកើតសព្វព្រៃ   ប្រាជ្ញប្រពៃមិនមានកើតសព្វស្ថាន ។

(៦) បណ្ឌិតោ សុតសម្បន្នោ   យត្ថ អត្ថិ បេ សុតោ

---

១ គត្ថ វិជ្ជា សិប្បំវាមហាគិ ទិស្សតិ ។ ២ មុត្តិកា,ត្តិ យេភុយ្យេន ទិស្សតិ ។

មហុស្សហោន ធំ បាន់ គន្ធព្វេ(១) សុតេសិតា ។

៧ បើគ្មានមាននរណាប្រាជ្ញច្បាស់ គប់សូត្រសិល្បសាស្ត្រគន់ទីណា
អ្នកស្វែងរៀនសូត្រៈសម្រាប់ ហៅត្រាចូលទៅទីនោះហោង ។

(៧) សិនេ សិប្បំ សិនេ ធនំ សិនេ បព្វតមារុឃំ
សិនេ កាមស្ស កោធស្ស សិនេ បញ្ច គុណេ គមេ ។

៧ រៀនសិល្បសាស្ត្រកុំទន់បណ្ដោយញាប់ ស្វែងទ្រព្យសន្សំកុំខ្ជិលខ្ជាន់
ឡើងភ្នំសន្សឹមកុំប្រញាប់ សេពកាមតាមកម្លាំងតិចៗក៏ ។
ខឹងហោះតិចៗកុំឲ្យស៊ុំ កាមគុណទាំង៥ ជាហេតុ
សម្រេចតិចៗហ្មើបតិចហោ គ្រោះសន្សឹមកុំបំភ្លេច ។

(៨) សុតិ សម្មុតិ សង្ខ្យា ច យោគា នីតិ វិសេសកា
គន្ធព្វា គណិកា ចេវ ធនុវេទា ច បូរណា
~~តិកិច្ឆា ឥតិហាសា ច ជោតិ មាយា ច ឆន្ទតិ~~(២)
ហេតុ មន្តា ច សទ្ទា ច សិប្បា អដ្ឋារស ឥមេ ។

៨ សិល្បសាស្ត្រទាំងឡាយ ១៨(៣) ក្នុងបាលីលោកចែកមាតិកា

១ គន្ធព្វេ ប៉ះ ពាវេះ ។ ២. កោរណាពោន្ទេ : សិប្បសាស្ត្រសកា គបេ,ឥៈបាហេ
វាគហោ ។

៣- សិល្បសាស្ត្រទាំង ១៩ នេះ ក្នុងទីនេះឃើញថា ១៩ ទៅវិញ: ១ សុតិ សេចក្ដីដឹងច្បាស់នូវសំឡេងរបស់សត្វទាំងឡាយមានសំឡេងស្រែកជាដើមថា សំឡេងយ៉ាងនេះល្អ យ៉ាងនេះមិនល្អ . ២ សម្មុតិ ដឹងច្បាស់នូវកំណើតរុក្ខជាតិដើមឈើជាដើម: ៣ សង្ខ្យា ដឹងនូវគម្ពីរលេខ: ៤ យោគោ ដឹងការធ្វើឧបាយការត្រៀមប្រែការ: ៥ នីតិ ដឹងនូវសិល្បសាស្ត្ររបស់ស្ដេច ៦ វិសេសិកា ដឹងនូវសេចក្ដីបរិបូណ៌ផ្លូវធ្វើឲ្យមានសិរីមង្គល: ៧ គណិកា ដឹងរាប់នក្សត្រឫក្សដឹងដំណើរផ្កាយ: ៨ - គន្ធព្វា ដឹងស្គាល់របៀបភ្លេង: ៩ តិកិច្ឆា ដឹងគម្ពីរពេទ្យ ; ១០ ធនុព្វេទា ដឹងសិល្បសាស្ត្របាញ់ធ្នូ ; ១១ បុរាណា ដឹងច្បាស់ថាទីនេះជាទីស្រុកចាស់ពីពេលចាស់ ; ១២ ឥតិហាសា ដឹងច្បាស់ពាក្យការដែលមុខទៅទិសនោះជាមង្គលជាដើម ; ១៣ ជោតិសា ដឹងច្បាស់នូវគម្ពីរព្យាករណ៍ គឺដឹងទាយថា មនុស្សកើតឆ្នាំនេះខែនេះ ឆ្នាំនេះល្អអាក្រក់: ១៤ មាយា ដឹងថាវត្ថុយ៉ាងនេះធ្វើការយ៉ាងនេះ មិនកើតបានក៏: ១៥ ហេតុ ដឹងច្បាស់នូវហេតុដែលកើតឡើង ដឹងផលដែលកើតឡើងពីហេតុ នោះ ; ១៦ មន្តា ដឹងច្បាស់នូវទីដែលនឹងបិទផ្លូវគោត្រើ ទីដែលពួកសត្វកុំកុដាស្រែបំការ ឲ្យបំពេញពល ; ១៧ យុទ្ធា ដឹងនូវពិធីចំបាំងសត្រូវ : ១៨ ចាសុណ្ណា ដឹងនូវគម្ពីរលោកវោហារ ; ១៩ ឆន្ទសា ដឹងច្បាស់នូវគម្ពីរដឹងបំពួនខ្មែរហេតុការដឹងពាក្យរលោក ធ្វើតាមបែបនេះ ( បំណិត្តបញ្ញក ) ។

សុគតិគឺព្រះមន្ទ្រស្លាប់កាសា
សម្បុគិតាព្រះជម្ពូសាស្រ្ត ៗ
សម្បិ្រគឺព្រះលេខបូកគុណហា
យោគាគឺព្រះការកាប់ចាំងផ្ទាក់
ទិតិគិចិតិឃកាកេប្រាណគ្គណ៍
ភេសសកាចាក់តាយដោគជ័យ ៗ
គន្ធព្វាព្រះភ្លេងប្រៀមឋីកសោក
គណិកាព្រះផ្លាត់ផោយព្រាមវៃ
ឥន្ទ្រកេងព្រះមន្ទ្រឥសិលប្រ៉ែស
បុរាណព្រះពៃលលកតា ៗ
គតិក្ខាព្រះពេចស្រេក្សាកោត
ឥតិហាសាយោគព្រះកាព្យ
ដោះគឺព្រះផ្តែវេចក្រ
សព្ទបាយាគឺយេះព្យាករណ៍ចិត ៗ
ធន្ទគិគឺព្រះធន្ទតិសាស្រ្ត
កេតុគឺប្រៀវគ្លាសត្វសត្វតាប់
បន្ទាគឺព្រះមន្ទ្របង្ហាប់
សទ្ទាគឺព្រះផ្លាប់ចិត្តអ្នកស្តាប់ ៗ
សព្វសាស្រ្តមិន១៨យោគ
បានតម្ររិតផលោកៗប្រដាប់
តែងតាំងខ្លួនឲ្យអ្នកផងគ្រាប់
រៀនចាប់ពុំស្រាប់ការលោកិយ ៗ

(៩) អប្បុដ្ឋោ បណ្ឌិតោ ហោតិ បឋិតោ ហោតិ បប្បិតោ
ការណោ បុដ្ឋោ អប្បុដ្ឋោបិ ពហុំ បិ ភណិតេ សទា[១]

៨ យាគិបណ្ឌិតពិតពេញប្រាជ្ញប្រាជ្ញ គ្មានគេហោកសាកសួរការនោះនា

១ ក្បួនខ្លះជា… បណ្ឌិតោ អប្បុដ្ឋោ ហោ… ការណេ បុដ្ឋោ អប្បុដ្ឋោបិ ពហុំវិកត្ថកោ សទា

ដូចស្រូវធំឥតគេដើរគោះរាយរាប់    បើគេស្រូវកាលណាជួបភ្លៀងធ្លាក់ ។
ជាតិពាលពិតឥតគេស្គាល់ប្ដូរស្រស់ ក៏លាទ់កង់ពង់ពោលឥតអាក់មិយាយ
ច្រើនកើនហួសផ្រុសធំណាក់    ចុះក្ដីក្បួនមិនលក្ខណ៍ព្រាក់សព្វកាល ។

(១០) យោគ្គកេសុ ច យំ សិប្បំ បរហត្ថេ ច យំ ធនំ
យថា កិច្ចេ បិ សម្បន្នេ ន តំ សិប្បំ ន តំ ធនំ ។

ព សិល្បសាស្ត្រឯណាមិនស្ទាត់ពិត នៅក្នុងស្មឹកកតែក្បួនសៀវភៅ
ទ្រព្យធនឯណាដែលបាននៅ    ធ្លាក់ទៅលើដៃអ្នកដទៃ ។
បើមានកិច្ចការណាដល់មក    សិល្បទ្រព្យនោះយកមកអាស្រ័យ
ពុំបានដូចចិត្តដែលឆ្ងាយដៃ    សិល្បទ្រព្យនោះនៃហៅគ្មានហោង ។

សុភាសិតថា:

ទ្រព្យមានលើកឲ្យគេខ្ចីទៅ    ចំណេះរបស់នៅតែក្នុងក្បួន
ប្រពន្ធនៅឆ្ងាយអំពីខ្លួន    "ដល់ជួនត្រូវការរកចិត្ត ។

(១១) ជលប្បមាណំ កុមុទនាឡំ កុលប្បមាណំ វិនយោបចារំ
ព្យត្តិប្បមាណំ កថិតវាក្យំ បថវិប្បមាណំ តិណាមិលាតំ ។

ចង់កុមុទប្រមាណទីជលស្ថាន វិន័យប្រមាណត្រកូលវង្ស

កថាប្រមាណប្រាជ្ញខ្លៅល្ងង់ ស្មៅល្អប្រមាណនៃពសុធា ។

វិទូប្រមាណផងម្រៀមទឹកពិនិត្យ ឲ្យដកព្រលិតកស់រៃផក

ប្រមាណត្រកូលអ្នកកាចជា ឲ្យមើលកិរិយាអាការចេញ ។

ប្រមាណអ្នកឈ្លាសវៃប្រាជ្ញប្រាយ មើលកាលនិយាយពោលមកមិញ

ប្រមាណប្រឹបតីដីដីដេញ មើលស្មៅខៀវចេញអាក្រក់ល្អ ។

សុភាសិតថា៖

ធ្វើស្រែចំការឲ្យមើលស្មៅ ទុកដាក់កូនចៅមើលផៅសន្តាន

ធ្វើទីលំនៅមើលភូមិស្ថាន បរិភោគប្រមាណមើលអាហារ ។

បុរាណគតិថា៖

១ សម្ដីបកភាសា កិរិយាបកត្រកូល

២ ត្រកូលសជាតិ ហរយាចសព្វជ ។

(១២) អប្បស្សុតោ សុតំ អប្បំ ពហុមញ្ញតិ(១) មានភិ

(១) បោរាណពោធ្ធកេ ៖ ពហុបញ្ញាតិ ទិស្សតិ ។

សិន្ធុទកំ អប្បស្សន្តោ កូបេ តោយំវ មណ្ឌូកោ(១) ។

០ ទៅព្រៀនរៀនគ្រាប់ស្ដាប់តិចតួច សំគាល់ថាខ្លួនស្រួចមិនចេះពាល់
មិនដឹងពុទ្ធពចន៍នៅសេសសល់ ដូចកល់កង្កែបបែបកំឡៀ ។
នៅក្នុងអណ្ដូងរណ្ដៅចល មិនដែលទៅស្គាល់សមុទ្រជ្រៅ
សំគាល់អណ្ដូងដែលខ្លួននៅ ថាជ្រៅថាធំលើសនានា ។

(១៣) បឋមំ ន បរាជិតោ សិប្បំ ទុតិយំ ន បរាជិតោ ធនំ
តតិយំ ន បរាជិតោ ធម្មំ ចតុត្ថំ កឹ ករិស្សតិ ។

៨ វ័យបឋមឲ្យខំរៀនវិជ្ជា វ័យទីពីរខំស្វាហ៍រកធនធាន
វ័យទីបីស្វែងធម៌បុណ្យព្រាណ វ័យទីបួនក្សូនគ្មានទីធ្វើអ្វី ។

(១៤) ព្យត្តា បុត្តកិមាលសេ អព្យត្តកោ ភារិហារិកោ
ព្យត្តកោ បូជិតោ លោកេ ព្យត្ត បុត្ត ទិនេ ទិនេ ។

កាព្យ ហៃបុត្រឧត្តម ចូរបាខះខំ រៀនសិល្បសាស្ត្រ បើខ្ជិល
យ៉ាងនេះ នឹងចេះកាលណា យូរទៅគង់ជា ខ្វះគេមិនខាន ។ បើ
បាបានចេះ គង់លោកិយនេះ គង់គេរាប់អាន បូជាមាសប្រាក់ យស
ស័ក្តិថ្កើងថ្កាន ចូរកូនរៀនអាន សព្វៗថ្ងៃហោង ៗ

(១) មណ្ឌូកៈ ដល់ ភូសេតៈកិ, បណ្ឌុកោ. ( សក្កោ ) អ អ.

(១៥) មាតាវេរី បិតា សត្រូ កេន ពាលេន សិក្ខិតា
សភាមជ្ឈេ ន សោភតិ ហំសមជ្ឈេ ពកោ យថា ។

៧ មានកូនមិនឲ្យកូនសូត្ររៀន   បំណេះរបៀនការនានា
មាតាលោកថាជាវេរ៍   បិតាទុកជាសត្រូវធំ   ៗ
កូនពេញប្រាណពាលពត់មិនឡើង   ហៅថាមិនប្រើក្នុងជំនុំ
ប្រៀបដូចកុកគ្រាន់ចូលទ្រនិ   កណ្ដាលជំនុំនៃពពួកហង្ស   ៗ

(១៦) កណ្ដកាគិរី កោ តិក្តំ កោ អញ្ជនា មិគក្ខាយំ
ឧប្បលស្ស បល្លវេ កោ សុគន្ធំ កុលបុត្តប្បោ
កោ បរិត្តយិ សមតិភាវោ ។

នរណាឡើយសម្រួបបន្លាកុំ   សភាពស្រួចៗសមកំណើតវា
នរណាឡើយដាក់ថ្នាំក្អកម្រិត   សភាពល្វីងៗជាធម្មតាតែង   ៗ
នរណាឡើយដាក់ថ្នាំកុងបក្កផល   សភាពក្លិននៃឧប្បលក្រអូបឯង
កុលបុត្រពេប្រែបួរប្ចួកថែង   សភាពរូបល្អឯងតាមកំណេ   ៗ
នៃ បន្លាស្រួចក្អិស្រួចៗនូវឯង   គ្មាននរណាចាត់ចែងសម្រួល
ក្អកម្រិតល្វីងៗឯងជាធម្មតា   គ្មាននរណាដាក់ថ្នាំតាំងគាំត   ៗ

ផ្កាឈូកប្រេលមានក្លិនក្រអូបឯង  គ្មាននរណាតាក់តែងរាក់ទាក់អប់
កុលបុត្រចេះឯងដឹងឯងសព្វ  គ្មាននរណាប្រាប់ប្រដៅរាំរៀន ។

(១៧) ន រសំ អកោតម្ពលំ អធនស្ស លង្កតម្បិ
អលោណកន្ត ព្យញ្ជនំ ព្យាករណំ អសិប្បស្ស ។

៨ ស្លាម្លូឥតកំបោររសគ្មាន គ្រឿងតែងប្រាណឥតរសអ្នកគ្មានទ្រព្យ
សម្លឥតអំបិលរសមិនជាប់ ព្យាករណ៍គាប់ឥតរសបុរសកំឡោ ។
(ពុំនោល) ថ្វី កំបោរជារសម្លូ គ្រឿងសព្វស្ត្រាជារបស់អ្នកល្អ
អំបិលជារសសម្ល ព្យាករណ៍ទីពឹងជារសអ្នកមានវិជ្ជា ។

ក្នុងលោកន័យថា:

អំបិលជារសសម្ល ស្រីល្អប៉ុនជារសនៃច្បាប់ត្រៃ ។

(១៨) សុស្សូសាសុតសម្បន្នោ សុតបញ្ញាយ វឌ្ឍតិ
បញ្ញាយ អត្ថំ ជានាតិ អត្ថោ ញាតោ សុខាវហោ[១] ។

៨ សុស្សូសាកូនណាខ្វល់ខ្វាយត្រាប់ រៀនរៀនស្ដាប់ចេះដឹងដោយបញ្ញា
ជមិអាចថ្វីផលចេះនោះជួយអាត្មា នាំឲ្យបានមហាក្សេមសុខ ។

(១៩) ភោជនា មេថុនា និទ្ទា គោណេ បោសេ បិ វិជ្ជតិ

១ ធម្មនីតិយាមួយ: សុស្សូសា សុតវឌ្ឍតា, បញ្ញាយ វឌ្ឍន៍ វឌ្ឍតិ: បញ្ញាយ អត្ថំជានាតិ ញាតោ អត្ថោ សុខាវហោ: លិខិតោ ។

វិជ្ជា វិសេសោ បោសស្ស ហីនោ គោណសមោ ភវេ ។

គោជនរបេចុនធំធំក្រៃ    មានគុណនាគោព្រាន់ឥតបុរស
វិជ្ជាវិសេសរបស់ប្រុស    វិជ្ជាហីនយសស្មើគោទៅ ។
ថ្ងៃ បរិភោគកេហាគោសេពកាម    ដេកត្រែកញ្ជាប់ញយាំមិនឈប់នៅ
ជាទុក្ខគោនឹងបុរសរស់ចូលទៅ    ប្រុសបាន់សិល្បសាស្ត្រទៅវិសេសក្រៃ
ពេញប្រុសពាក្យពេរះវិជ្ជាការ    ការរសារផ្ទស្ការស្គាល់
ទុកស្មើគោគេប្រើផ្ទុកសព្វថ្ងៃ    នឹងរកស្រ័យក្តីទុក្ខកស្មុខគ្មាន ។

(២០) នត្ថិ វិជ្ជា សមំ មិត្តំ នត្ថិ(១) ព្យាធិសមោ រិបុ
នត្ថិ(១) អត្តសមំ បេមំ នត្ថិ(១) កម្មសមំ ពលំ ។

ចំណេះស្មើដោយវិជ្ជានោះពុំមាន    សត្រូវប្រាណមិនស្មើដោយព្យាធិ
ស្រឡាញ់គ្រប់មិនស្មើកាយខ្លួនឯង    កម្លាំងអ្វីមិនស្មើកម្មបុរាណ ។
ថ្ងៃ មានចំណេះមិនស្មើមានវិជ្ជា    មានភោគាមិនស្មើពាលគន្ថាន
ស្រឡាញ់អ្វីមិនស្មើស្រឡាញ់ប្រាណ    កម្លាំងអ្វីមិនស្មើស្មានកម្លាំងកម្ម ។

សុភាសិតបា:

ភោគអ្វីមិនស្មើទីភោគឃ្លាន    ទានអ្វីមិនស្មើទានធម៌ទេសនា

---

១· ពេញណាណហេតុគេ ឥតពិដ៏ ទ័សព្វដ៏ ។

ហានអ្វីមិនស្មើហានបញ្ញា ផ្កាអ្វីមិនស្មើផ្កាចិត្តផ្កាបុណ្យ ។
រហ័សអ្វីមិនស្មើចិត្តផែលទឹក មុតអ្វីមិនស្មើទឹកហូរហោរគន្ធ
ធ្ងន់អ្វីមិនស្មើព្រះគុណធ្ងន់ ខំអ្វីមិនស្មើធ្ងន់ប្រពន្ធប្រើ ។

(២១) ហំសោ មជ្ឈេ ន កាកានំ សីហោ គុន្នំ ន សោភតេ
គទ្រភមជ្ឈេ ន[១] តុរង្គោ ពាលមជ្ឈេ ន បណ្ឌិតោ ។

ហង្សនៅកណ្ដាលហ្វូងកាកា សីហានៅកណ្ដាលនៃហ្វូងគោ
តុរង្គៈនៅកណ្ដាលហ្វូងគទ្រភា បណ្ឌិតនៅកណ្ដាលពួកពាល ។
ថៃ

—— កជហង្សនៅក្នុងហ្វូងក្អែក កជសីហាចូលសែកនៅក្នុងហ្វូងគោនានា
ពុំនោល

កជាសេយ្យនៅក្នុងហ្វូងលា អ្នកមានប្រាជ្ញានៅក្នុងពួកពាលសាមាន្យ
សត្វ៤នេះនៅខុសស្ថាន បានគ្នាទានពុំមានថ្កុំថ្កើនរុងរឿង ។

(២២) យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វិ សូបរសំ យថា ។

---

១ ពោភកណពោទ្ធកេ ខា·តិ ទិស្សតិយេវ ។

ឲ្យ កាលទៀតចូលទៅជិតបណ្ឌិត គាត់សង់ជំនិតលងឹអនេក
មិនដឹងនិងសេចក្ដីការជំងាក ដូចអែកមិនដឹងរសសម្ល ។

(២៣) មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

ជាតិប្រាជ្ញនៅជិតបណ្ឌិតប្រាជ្ញ ដូចពាក់គាបទេះឈមិកាច
ដូចបណ្ដាគនិងរសនៃការហារ ដូចត់ទារហើរប្រែកាចដឹងបាន ។

(២៤) វិជាធនំ ន ចោរេហិ គរុភា គវ្ពាបភូមិយំ
បណ្ឌិតន្ទុគុ វិណាចោ វិទេសគមនោ ធុរំ ។

៨ យោគាពុបានទៀតទ្រព្យស្នាក់ ទេពុសត្រូបតយុទ្ធទៅតុំបាន
ជាតិប្រេតប្រាជ្ញទៀតគប្បីរើកគេន ពុំគាចរែងឲ្យធំបានខានចោរា ។
នាយពោលកំផលទៀតប្រើយានទេះ ទំលំពោរការ:ទៅឆ្ងាយពុំបានណា
អ្នកទីដ៏ទៅគាន់ប្រទេសទីនានា ទៀតយានទីដ៏យាត្រាទៅតុំបាន ។

(២៥) ធនធាសំ មហោតាបំ យវេ ទុប្ចរិតាធិ ប
វិញ្ញុតញ្ញូ អវេកជំ បណ្ឌិតោ ធ បកាសយេ ។

យំស្រែឡះថាស្រឡាញ់ៗក៏ ទាល់តែយក្តាមរេបចង្កាថាឯងៗ ។
មនុស្សកំឡៅកម្លាថាខ្លួនបេះ មានប្រាជ្ញាគ្រះស្គួររៀនឲ្យថ្លៃ
ចលបំពេញរនឹងនេះពេលបង្វែ បន្ទប់ត្រូវបន្ទប់ស្តាំមិនឲ្យស្ទើរ ។

(កាកគតិ ភាពរាវខ្ទះប្រែថា "កន្លែងកាលវេក្តកនាបយកទៅ")

(៣១) ន តិត្តិ រាជា ធនេហិ បណ្ឌិតោ បិ សុភាសិតេ
ជលេ សាគរោន តិត្តិ បក្កុ បិ បិយទស្សនេ ។

ស្តេចមិនឆ្អែតសម្បត្តិណាទេ ប្រាជ្ញមិនឆ្អែតសុភាសិតតូចដីកា
មហាសមុទ្រមិនឆ្អែតស្ទឹងនានា ន័យនេត្រាមិនឆ្អែតគន់រូបគាប់ ។

(៣២) រូបយោព្វនសម្បន្នោ វិសាលកុលសម្ភវោ
វិជ្ជាហីនោ ន សោភន្តិ និគ្គន្ធា ឥវ កឹសុកា ។

កុលបុត្រប្រិយូណ៌រាយរូបទង់ កើតក្នុងត្រកូលកមសក្តា
គោតខ្ទាំទ្វេះមិនចេះសិស្សសាស្ត្រា ប្រៀបដូចផ្កាតាវទាំងឥតក្លិនក៏ ។

(៣៣) ហីនបុត្តោ រាជបុត្តោ ពាលបុត្តោ ច បណ្ឌិតោ
អធនស្ស ធនំ ពហុំ បុរិសោ មារិមញ្ញេ ។

កូនអ្នកទាបឡើងជាកមាត្យស្តេច   កូនពាលឡើងសម្រេចជាប្រាជ្ញបាន
អ្នកក្រក្រឡើងមានទ្រព្យធនធាន   ប្រុសកុំមានប្រមាថមើលងាយគេ ។

(៣៤) យោ សិស្សោ សិប្បលោភេន ពហុំ គណ្ហាតិ តំ សិប្បំ
មូគោវ សុបិនំ បស្សំ កថេតុំបិ ន ឧស្សហេ ។

សិស្សឯណាលោភរៀនរៀនច្រើនបច   ចាំមិនស្ទាត់មាត់មិនស្ទួនថ្លែងពុំបាន

ដូចមនុស្សគយល់សប្តិឃើញសព្វស្ថាន   ថ្លែងពុំបានវិវាទចិត្តអឹះអឺយ ។

(៣៥) ន ភញ្ជិតុំ កុម្ភការោ កុម្ភំ ឃដេតិ សោភណា[១]
ន ទិបិតុំ អបាយេសុ សិស្សានំ វុឌ្ឍិការណា ។

នាយស្មូនឆ្នាំងដំឆ្នាំងគាំងឲ្យល្អ   គ្រូនឹងគាំងក្រយសិស្សឲ្យសិក្សា
នឹងឲ្យធ្លាក់អបាយនោះគាលណា   ក្រយប្រាជ្ញាជាហេតុចំរើនសិស្ស ។
ថ្វី   នាយស្មូនគាំងដំគាំងគាំងប្រាជ្ញា   នឹងឲ្យស្រាំប្រែះធាតនោះក៏ទេ
ដំគោះនោះបង្ហាញលក់ឲ្យគេ   ដូចអាចារ្យក្រយដើរសិស្សសិក្សា ។

---

១ ហោកណាហោត្ថកេ: អយំ ទុតិយពាឋោ, ........ សោភេតុំ កុម្ភំ ឃដតិ គតិ ទិស្សតិ ។ ភាគា ឥមិនា សទិសា ហោន្តិ ។

ដេរកាយនោះនឹងឲ្យសិស្សអន្តរាយ ធ្លាក់ទៅក្នុងអបាយកំទេណា
ដេរកាយនោះជាហេតុឲ្យវិន្យាសា មានវិជ្ជាចំរើនដល់កូនសិស្ស ។

(៣៦) តគ្គរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ,
(១) បត្តា សុរភី វាយន្តិ, ឯវំ ធីរូបសេវិតា ។

ជនឯណាវេចរុំនូវគ្រឹស្នា ដោយស្លឹកឈើធម្មតាក្រជាស
ក្លិនគ្រឹស្នាក៏ផ្សព្វផ្សាយពេញពាស ក្រអូបជាសដល់ជនអ្នកវេចនោះ ។
មិនប៉ុន្មានប៉ុណ្ណោះពោះស្លឹកវេច ក៏ជាប់ក្លិនដាសលេចឡើងចំពោះ
ដូចបុគ្គលគប់ប្រាជ្ញសាចក្តីចុះ បានឧបមេយ្យដូច្នោះប្រាជ្ញគួរដឹង ។

## បណ្ឌិតកណ្ឌោ និដ្ឋិតោ

កណ្ឌនៃបណ្ឌិតចប់បរិបូណ៌

ក្នុងបណ្ឌិតកណ្ឌនោះ មានគាថា ៣៦ គាថា

---

១ បោរាណបោត្ថកេ៖ ឥតោបរំ បី សត្ថោ ទិស្សតិ ។

## សុជនកណ្ឌទី ២

(១) សព្ភិរេវ សមាសេថ, សព្ភិ កុព្វេថ សន្ថវំ;

សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលណាគប់សេពជាមួយសប្បុរស សោមនស្សស្មគ្គគប់ប្រាជ្ញប្រាជ្ញ ការពង់ធីសេធបីរបស់សប្បុរសទាំងឡាយ បុគ្គលនោះកើតឆ្ងាយផុត បាបកម្ម ។

(២) ជហ ទុជ្ជនសំសគ្គំ, ភជ សាធុ សមាគមំ;

ករ បុញ្ញមហោរត្តំ, សរ និច្ចមនិច្ចតំ ។

(ក្របា) ហៃទៅជាតិពិសី ចូរលះកុំប្រឡូកទៅ ដោយជនពាលឡើយ ចូរគប់ទៅនឹងសប្បុរស ។ ចូរធ្វើបុណ្យគ្រប់ព្រឹកល្ងាច សព្វគ្រប់ថ្ងៃគ្រប់រាត្រី ចូរបោះបង់សេចក្ដីអស់ នឹករឭកព្រះត្រៃលក្ខណ៍ ។

(៣) យថា ឧទុម្ពរបក្កំ ពហិរត្តកមេវិប៊

អន្តោ កិមិលសម្បុណ្ណំ ឯវំ ទុជ្ជនហទយោ[១] ។

(កាពគត់) ទុទ្ទុំ សម្បុរក្រៅ ក្រហមរលង់ ខាងក្នុងពេញ ទៅដង្កូវមមង់ ដូចមនុស្សទុជ្ជន ចិត្តផ្សព្វផ្សា ។

១ ធម្មនីតិបដិរូបៈ យថា ឧទុម្ពរបក្កា ពហិរត្តកមេវ ច អន្តោកិមិលសម្បូរណា ឯវំ ទុជ្ជនធម្មតា គតិទិស្សតិ ។

(៤) យថា បិ បទុមា បត្តា ពហិកណ្ណកមេវបិ
អគ្គោ អមិតសម្បន្នោ ឯវំ សុជនបាទយោ[១] ។

(ការកត់) ផ្កាឈូកធំ សម្បុរក្រហំ ប្រែប្រាងបទ្មា ខាងក្នុង
សឹងក្រុប ក្រអែបពិសា ដូចអ្នកសន្ធា ចិត្តជាសប្បុរស ។

គាថានេះឈ្មោះវសន្តតិលកឆន្ទ ១៤ តួ ១ បាទ

(៥) សុក្ខោ បិ ចន្ទនតរុ ន ជហាតិ គន្ធំ,
នាគោ គតោ វណមុខេ ន ជហាតិ លីឡំ,
យន្តេ គតោ មធុរសំ ន ជហាតិ ឧច្ឆុ,
ទុក្ខោ បិ បណ្ឌិតជនោ ន ជហាតិ ធម្មំ ។

ជាតិខ្លឹមចន្ទន៍ទោះស្ងួតក្រៀមក្រញង់ មិនលះបង់ក្លិនក្រអូបសុគន្ធា
ដំរីសារទោះចូលសឹកយុទ្ធនា មិនលះបង់លីលាល្អក្រាយ ។
ជាតិអំពៅទោះនៅកន្លែងយន្តគាប មិនលះបង់សភាពរសផ្អែមសាយ
ជាតិបណ្ឌិតទោះមានទុក្ខក្នុងកាយ មិនដែលណាយលះបង់ព្រះធម៌ថ្លៃ ។

---

១ ធម្មនីតិយម្បិ យថា ប បទុមា បត្តា ពហិកណ្ណកមេវ ប អគ្គោភយតប្បរណា ឯវំ សុជនធម្មតា ឥតិលិខិតា ។

(៦)សីហោ នាម ជិឃច្ឆា បិ បណ្ណានិ ន ខាទតិ
សីហោ នាម ជិឃច្ឆា បិ គោមំសំ ន ខាទតិ ។

រាជសីហ៍សត្វខ្ពស់ទោះអត់ឃ្លាន ក៏ពុំបានបរិភោគស្លឹកឈើស្មៅ
ឈ្មោះសីហៈទោះស្គមទ្រមហូរសៅ ប៉ុន្តែនៅមិនស៊ីសាច់ដំរី ។

(៧) កុលជាតោ កុលបុត្តោ កុលវង្សានុរក្ខតោ(១)
អត្តនា ទុក្ខប្បត្តោបិ ហីនកម្មំ ន ការយេ ។

កុលបុត្រកើតក្នុងត្រកូលវង្ស រក្សាពូជពង្សវង្សសម្មា
ទោះខ្លួនទ័លផល់ទុក្ខទោសយ៉ាងណា គាំងចិត្តាមិនធ្វើការពីបាប ។

(៨)បណ្ឌិ៍ សំគលំ លោកេ តតោ បណ្ឌិ វ សីតលំ
បណ្ឌិតបណ្ឌិសំគម្ហា សាធុ វាក្យំ សុភាសិតំ ។

ជាតិខ្ទឹមបន្ទំត្រជាក់ក្នុងលោកា ដូងចន្ទ្រាត្រជាក់លើសខ្ទឹមបន្ទំ
សុភាសិតសប្បុរសពោលធម្មក្ខន ត្រជាក់លើសខ្ទឹមបន្ទំនឹងចន្ទ្រា ។

(៩) ឧទេតិ ភាណុ បច្ចិមេ មេរុវាឆាបិ នមតិ
សីតលំ យទិយមគ្គិ បត្តគ្គេ ច ឧប្បលំ

---

១ ពោភណពោត្តកេះ ទុញ្ញោ បញ្ញោពិ គតិទិស្សតិ ។

វិកសេ ន វិបរិតា　សាធុវាចា កុទាបនំ ។

កាណ្ឌវង់ព្រះកូនទិសបច្ចិមា　សុមេរគីរីតោរទន់ទៅ
ក្នុងកូនយមលោកនរកផ្សេង　កំដៅប្រែទៅជាត្រជាក់ស្រួល ។
ទប្រលប់ផ្កាផ្កាប្រែទុប　រីករលើខ្លួនក៏ឃើញវិបរិត
ពាក្យតាសប្បុរសពោលចេញពិត　មិនប្រែវិបរិតក្នុងកាលមួយ ។

(១០)សុខំ វុត្តស្ស ឆាយាវ តតោ ញាតិ មាតាបិតា
តតោ អាចរិយោ វញ្ញោ តតោ ពុទ្ធស្ស អនេកទា។

ម្លប់នៃព្រឹក្សព្រៃធំបានសុខ　ម្លប់ម្ដាយឪពុកញាតិកា
វិសេសលើសម្លប់នៃព្រឹក្ស　ម្លប់គ្រូអាចារ្យលើសម្លប់ញាតិ ។
ម្លប់ស្ដេចលើសម្លប់គ្រូអាចារ្យ　ម្លប់ព្រះឈ្នះមារបរមនាថ
វិសេសលើសម្លប់ខត្តិយជាតិ　ព្រោះស្អាតវាតបង់សំសារចក្រ ។

(១១)ភមរា បុប្ផមិច្ឆន្តិ គុណមិច្ឆន្តិ សុជនា
មក្ខិកា បូតិមិច្ឆន្តិ ទោសមិច្ឆន្តិ ទុជ្ជនា ។

(កាកគតិ)　កន្ទុំរុយផ្កា　ជនល្អប្រាជ្ញា　ការគុណប្រយោជន៍

ព្រោះបានសិរីសួស្តី បន្ទាយការសោច ជនខ្លះជាតិរហាច ស្រដៀងរោគា ។

(១២) ទុជ្ជនោ ទោសមាទាយ ទុគ្គតឹ សូករោ
សុជនោ សុគុណគ្គាហោ ហង្សា ខីរមិវម្ពុតោ(១)។

ជនខ្លះកាន់យកតែទោសទុក្ខ ដូចគលជ្រូកស្រកប៉ុនការចម
ជនល្អកាន់យកគុណឧត្តម ដូចហង្សប៉ុនបិចកទឹកដោះ ។

(១៣) មាតា ហីនស្ស ទុក្កលោ បិតា ហីនស្ស ទុក្រិយា
ឧភោ មាតាបិតា(២) ហីនា ទុក្កលា ច ទុកិរិយា ។

បើមាតាហីនជាតិកើតបុត្រា បុត្រនោះមានវាចាសាបាប
បើបិតាហីនជាតិមាត្រគុណកាព បុត្រនោះខាបកិរិយាអាក្រក់នៅ ។
បើទាំងពីរហីនជាតិទាំងពីរនាក់ កូននោះអប្រលក្ខណ៍ទាំងពីរផ្លូវ
ទាំងកិរិយាការយាទក៏អាក្រក់សៅ តាមគន្លងមែឪផ្លូវដូចគ្នា ។

(១៤) ~~មាតា សេដ្ឋស្ស សុភាសា បិតា សេដ្ឋស្ស~~ សុកិរិយា
ឧភោ មាតាបិតា សេដ្ឋា សុភាសា ច សុកិរិយា ។

បើមាតាប្រសើរកើតបុត្រា បុត្រនោះមានការសាពាក្យពីរោះ
បើបិតាប្រសើរផតហ្វូងនោះ ឯបុត្រនោះប្រកបកិរិយាពិត ។

១- អប់រំ ធាតុធម្ម ជោគណពោះ ៥ ពេកិ ។ ២- ឧភោ មាតាបិតរោ គតិ លេខាលៀត
ទំព្រួក ។

បើម៉ែឪឧត្តមទាំងពីរពេល    កូននោះប្រែកប្រែងអ្នកសុចរិត
ទាំងភាសាកិរិយាគារពបណ្ឌិត    បានជាមិត្រសប្បុរសក្នុងលោកិយ ។

(១៥) សង្គាមេ សូរមិច្ឆន្តិ មន្តិសុំ កុតុហលេ
បិយញ្ច អន្នបានេសុ អត្ថេ កិច្ចេ សុបណ្ឌិតេ ។

នាកាលកើតកលិយុគយុទ្ធនា[1]    ព្រះរាជាត្រូវការអ្នកក្លាហាន
នាកាលកើតពាក្យនិយាយប្រាណ    ទ្រង់ចង់បានពេជ្របេះបន្តសុខា ។
នាកាលពេលបរិភោគអាហារវិញ    ចង់បានមិត្រសំឡាញ់បរភោគា
នាកាលកើតកិច្ចអាថ៌ប្រែស្នា    សឹងប្រាថ្នារកប្រាជ្ញអាចដោះស្រាយ ។

(១៦) សុនខោ[2] សុនខំ ទិស្វា ទន្តំ ទស្សេតិ ហិំសិតុំ
ទុជ្ជនោ ទុជ្ជនំ ទិស្វា រោសយំ ហិំសមិច្ឆតិ ។

សុនខាបែរយល់សុនខ    ក៏តាំងសំញេញញបង្ហាញធាធា
ជនខ្ជួយល់ជនខ្ជួចគ្នា    ប្រាថ្នាសឹងយាយីគ្នាឯង ។

(១៧) មា ច វេគេន កិច្ចានិ កាវេសិ ភា[3] ការាបេសិ

---

១_ កាលសម័យដែលប្រកបដោយទោស ដោយវិបត្តិ. វិបរិតផ្សេងៗ ហៅថា កលិយុគ. តាមក្បួនក្នុងប្រទេសឥណ្ឌា ដែលប្រកាន់តាមសណ្ដាប់អំពីបូរាណប្បអង្វែងណាស់មកហើយ ថាយុគមាន ៤ យ៉ាង គឺទី១ ក្ឫតយុគ, ទី២ ត្រេតយុគ, ទី៣ ទ្វាបរយុគ, ទី៤ កលិយុគ ។
២ បាឋណាបាឋ្ឋកេះ ទុជ្ជនា...៖ ហិំសមច្ឆន្តិ ទិស្សតិ ។ ៣_ ឥត្ថ ការេសិ ការាបេសិ ភាតិ បាឋោ អាគតោ ។

សហសា ការិតំ កម្មំ មន្តោ បច្ឆានុតប្បតិ ។

ជនធ្វើការប្រញាប់ដោយខ្លួនឯង ឬចាត់ចែងប្រើគេឲ្យធ្វើផង
ញ៉ាំងអ្នកទៅឲ្យក្តៅចិត្តប្អូហ្ន ដោយហេតុនូវការរហ័សក្នុងកាលក្រោយ ។

(១៨) កោធំ វិហិត្វា ន កទាចិ សោចតិ
មក្ខប្បហានំ(១) ឥសយា វណ្ណយន្តិ
សព្វេសំ ផរុសវចនំ ខមេថ
តំ ខន្តឹ ឧត្តមមាហុ សន្តោ ។

ជនឯណាកំចាត់ក្តីក្រោធបាន ជននោះគ្មានសោកសាន្តក្នុងលោកិយ
ព្រះឥសីសរសើរអ្នកគប្បី លះបង់ក្តីលុបគុណគេបសត្រ ។
អ្នកឯណាអាចអត់ផរុសវាច មិនវាចាតបដោយពាក្យបេសុញ្ញ
សប្បុរសសរសើរអ្នកនោះណា ថាជាខន្តិគុណដ៏ឧត្តម ។

១ [illegible] ។

(១៩) ទុក្ខោ និវាសោ សម្ពាធេ ហីនេ អសុចិសង្កតេ
តតោ អារីម្ហិ អបិយេ តតោ បិ អកតញ្ញុតា ។

ទីលំនៅចង្អៀតគេជ្រៀតមិនចុះ សំណិតម្រះហ៊ាយសាកសពសោចក្រៃ
តែងនាំមកនូវទុក្ខកាចក្រៃ តែការស្រ័យនៅបានជាមធ្យម ។
ទីលំនៅៗរួមមនុស្សកាចិ ជាទីទិសត្រូវមិនគិរម្យ
ជាទុក្ខលើសទីពេញកាចម ទង់សម្ពុំទំនៅសៅរិទាន ។
ទីលំនៅៗរួមអកតញ្ញូ ជាទុក្ខរកអ្វីស៊ីទឹងប្រៀបបាន
លើសលែងទីផែលរួមកាក់ព្រាល ព្រោះសន្តានមក្ខាជាទោរង ។

(២០) ឱវទេយ្យានុសាសេយ្យ[1] បាបកា ច និវារយេ,[2]
សតំ ហិ សោ បិយោ ហោតិ, អសតំ ហោតិ អប្បិយោ ។

កាចារព្រេះខុនានហាមប្រដៅ បុគ្គលទៅថ្ងៃលះបង់បាបបាន
កាចារព្រនោះជាទីគាប់រាប់អាន នៃសន្តានសប្បុរសទាំងអស់គ្នា ។
តែពុំគាប់ចិត្តនៃអសប្បុរស ព្រោះពុកអសប្បុរសស្ងែងពាលា
ស្រឡាញ់តែអំពើបាបវេក ផ្សូវស្មូគាំជាទីស្អាទសប្បុរស ។

១ ពោរណពោឌ្ឍពោ ឱវទេយ្យ អនុសាសេបា្យតិទ័ស្សតិ ។ ២ ធម្មវណ្ណនាឈប់ប្រូះ អសុត្តា ច និវារយេ'តិ ទាយតិ ។

(២១) ទុប្បុំ រត្តិវិវេកេ   ល្បុំ ភោជនេ ធិត្តយោ
គិបិ អប្បកទានេន វិរមេន សមំ ធិយោ ។

*ឈ្មោះអ្នកខ្ចីស់ដោយត្រីនបន្ទុំព្រាណ   ឈ្មោះអ្នកក្លាហានដោយចំណាយ*
*ឈ្មោះអ្នកខ្ញុំព្រាយដោយឲ្យសម្បុរាយ   ឈ្មោះអ្នកស្មើគាយដោយពាក្យពារ ។*

(២២) ន វិតំ វិតវិញ្ញាត្រ ធនំ សញ្ញុស្ស ទុប្បតេ
វិតំ ហិកំ វិ វេគតិ សព្ទុំ សង្ឃស្ស វេគតិ ។

*កាចារ្យមិនពោលពិសឆាំង   ថាជាពិសលើសនៃពិសទ្រព្យសង្ឃ*
*ពិសឯទៀតកាចសម្លាប់តែក្នុង ។   ពិសទ្រព្យសង្ឃកាចសម្លាប់ផុតឡូរៗ*

(២៣) ធិនេន វត្ថុំ ជាគត្តិ ពលិគទ្ធព្ទ វិហេន
ទុហេន បិញ្ចាំ ជាគត្តិ ភាសមានេន បណ្ឌិតំ ។

*បង់អ៊ីអីសេះលឿនដោយរត់ទៅ   បង់អ៊ីគោគ្រាន់ដោយរទេះ*
*បង់អ៊ីទឹកដោះដោយត្រៀត   បង់អ៊ីព្រាជ្ញដោយរាព ។*
*(រ៉ា) សេះជាឲ្យស្ទុះប៉ះលកិច្ចរ៉ាង   គោឲ្យផ្ទុកឲ្យធ្ងន់ប៉ះមើលវា*
*ទឹកដោះរូតឲ្យមើលបុងបង   ហេតាឲ្យស្តាប់សព្ទនិយាយ ។*

(២៤) ធនំ អប្បប្បំ សោធុពំ ភូបេ ភរិ វិ ធិសព្ទយោ

ពហុម្បិ អសាធូនំ ធន ភវតិ អណ្ណវេ ។

ទ្រព្យរបស់សប្បុរសទោះតិចតួច　បានជាប្រយោជន៍ជននានា
ដូចទឹកអណ្តូងស្រះសាបថ្លា　អស់មហាជនផឹកផងអាស្រ័យ ។
ទ្រព្យអសប្បុរសទោះមានច្រើន　ពុំបានចំរើនអ្នកដទៃ
ដូចទឹកសមុទ្រមានសេសប្រៃ　មនុស្សផងអាស្រ័យផឹកពុំបាន ។

(២៥) នាបី[១] បិវន្តិ នោ នជ្ជោ[២] រុក្ខា ខាទន្តិ នោ ផលំ
វស្សន្តិ ក្វចិ នោ មេឃា[៣] បរត្ថាយ សតំ ធនំ ។

ទន្លេស្ទឹងស្ទួលមិនផឹកទឹក　ដើមព្រឹក្សមិនស៊ីផលឯផល
មហាមេឃមិនធ្លាក់នូវភ្លៀងខ្យល់　ក្នុងបណ្តាលឯណាមួយដំបន់ ។
គឺឯទ្រព្យសប្បុរសផងទាំងឡាយ　សំដំចំរើនផ្សព្វផ្សាយដល់មហាជន
ប្រយោជន៍សប្បុរសប្រកបធន　បំពេញបុណ្យផ្លូវកុសលដល់ទីត្រាន ។

(២៦) អបត្តេយ្យំ ន បត្តេយ្យ អបិត្តេយ្យំ ន បិត្តេយ្យ
សភាវមេវ បិត្តេយ្យ កាលំ មោឃំ អតិបេយ្យ ។

---

១ អញ្ញពោត្ថកេ អប្បិ,ស្ពិ យេភុយ្យេន ទិស្សតិ ។ ២ នទិតព្វេតស្ស ទិ- សទ្ទស្ស លោ, ទេសោ ហោតិ សហ យោ- វិភត្តិយា ។ ៣ ឥច្ចុទីរិយបៀនៈ មេឃោ ភវាចិ នោ សស្សំ ផលិបាលេះ អាគតោ ។

កុំប្រាថ្នាការមិនគួរប្រាថ្នាបាន　　កុំគិតរកការមិនគួរបុគ្គលគិត
គួរគិតតែការសភាពរបស់ពិត　　កុំប្រាថ្នាកុំទៅគិតការទទេ ។

(២៧) អបត្ថិតំ បិ ភវតិ　　បត្ថិតំ បិ វិនស្សតិ
ន ហិ ចិន្តាមយា ភោគា ឥត្ថិយា បុរិសស្ស វា ។

ការមិនគិតក៏កើតមានឡើងបាន　　ការគិតរកនក៏ប្រែវិនាសរលស់
ភោគសម្បត្តិនៃស្រីឬបុរស　　ស្រេចដោយគិតទាំងអស់នោះក៏ទេ ។

(២៨) អសន្តស្ស បិយា ហោន្តិ[1] សន្តេ ន កុរុតេ បិយំ
អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។

ខាងជនស្រឡាញ់អសប្បុរស　　មិនសោមនស្សត្រើសប្បុរសផង
ត្រេកតែធម៌អសប្បុរសសេពសៅហ្មង បទនេះហៅថាជាហេតុអន្តរធាន ។

## សុជនកណ្ឌោ និដ្ឋិតោ

កណ្ឌនៃជនអ្នកល្អចប់តែប៉ុណ្ណោះ

ក៏ផ្សុំជនកណ្ឌនេះ បានគាថា ២៨ គាថា

———

១ លោកពុកពោធ្លើ អសន្តស្ស ពិយោ ហោន្តិ ន ទិស្សតិ ។ អយំ បាឋោ បករណ សុត្តន្ត សាធេតិ ។ បរាភវសុត្ត បញ្ហា អដ្ឋកថាយំ ។ សោ បិ អសន្តោ អស្ស ឥតិ បទច្ឆេទំ កាតព្វោ ។

## ពាលទុជ្ជនកណ្ឌទី ៣

(១) អតិបិយោ ន កាតព្វោ ខលោ កោតុហលង្គតោ
សិរសា វហមានោបិ អឌ្ឍបូរោ ឃដោ យថា ៕

កុំត្រូវមិត្រស្និទ្ធស្នាលដោយមនុស្សពាល គាត់នោះអាចធ្វើការកោហល
ដូចក្អមទឹកកន្លះគឺបុគ្គល លើកដាក់លើក្បាលហើយច្រូលទៅ ៕

(២) សប្បោ ទុដ្ឋោ ខលោ ទុដ្ឋោ សប្បា ទុដ្ឋតរោ ខលោ
មន្តោសធេហិ សោ សប្បោ ខលោ កេនុបសម្មតិ ៕

ពស់កាចអាចទ្រុស្តពោះវាំ ពេទ្យកែដោយថ្នាំអាចស្ងប់បាន
មនុស្សកាចលើសពិសពស់សាហាវ្យ ពុំមានអ្វីកែបានស្ងប់ស្ងាត់ឡើយ ៕

### សុភាសិតបាៈ

ត្រង់ពុតមនុស្សពាលពេទ្យនឹងពត់ ដោយមន្តថ្នាំឱសថពុំបានឡើយ ៕

(៣) យោ ពាលោ មញ្ញតិ ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី ស វេ ពាលោ តិ វុច្ចតិ ៕

ពាលឯណាដឹងខ្លួនថាពាលពិត ពាលនោះហៅបណ្ឌិតដោយនុយោគ
ពាលឯណាគន់ខ្លួនថាប្រាជ្ញប្រាក ពាលនោះឯងលោកហៅថាពាលោ ៕

(៤)[(១)] មធុវា មញ្ញតី ពាលោ, យាវ បាបំ ន បច្ចតិ;
យទា ច បច្ចតី បាបំ, អថ ទុក្ខំ និគច្ឆតិ ។

បាបពុំទាន់ឲ្យផលដល់កាលណា ពាលគិតថាបាបផ្អែមដក្បនោះ
បាបឲ្យផលកាលណា ទើបពាលត្រូវ ដល់ទុក្ខចំពោះកាលនោះឯង ។
(២) បាបពុំទាន់ឲ្យផលដល់កាលណា ពាលគិតថាបាបនោះដូចទឹកឃ្មុំ
លុះបាបកម្មឲ្យផលដល់ប្រជុំ ទើបពាលរងទុក្ខធំក្រៃកាលនោះ ។

(៥)ន សាធុ ពលវា ពាលោ សាហសំ វិន្ទតេ ធនំ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។

ពាលឯណាឥតបញ្ញាក្លាហានខ្លាំង បានទ្រព្យដោយកំឡាំងក្លាហានគេ
ពាលជននោះលុះចំលាយកាយក៏រេ ទៅកើតក្នុងនិរយនរកជ្រៅ ។

(៦)ឃរេ ទុដ្ឋោ ច មូសិកោ វនេ ទុដ្ឋោ ច វានរោ
សកុណេ ច ទុដ្ឋោ កាកោ នរេ ទុដ្ឋោ ច ព្រាហ្មណោ ។

កណ្ដុរប្រទូស្តផ្ទះ ស្វាមុះប្រទូស្តព្រៃ ក្អែកចៅដៃប្រទូស្តបក្សា ព្រាហ្មណ៍

១ បោរាណបោត្ថកេ, បត្តវតិ ទិស្សតិ ។

ប្រទូស្តផង (រឺ) កណ្ដាលស្រូវក្ដូងគឺហា ពានកប្រទូស្តពនាលី កាកោសស្រូវហូបចម្រៀ ព្រាហ្មណ៍ព្រឹទ្ធស្រូវក្ដូងមហាជន ។

(៧)ទីឃា ជាគរោ រត្តិ, ទីឃំ សន្តស្ស យោជនំ,
ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ។

យប់យូរនៃអ្នកមិនលក់ឯង យោជន៍យូរឆ្ងាយវែងនៃអ្នកបរ
សង្សារយូរឆ្ងាយនៃនិករ. ពាលពុំចេះធម៌ទៅនិព្វាន ។
(រឺ) ជនអ្នកដេកចង់ក្រោកថាយប់យូរ អ្នកដើរគិតគូរថាយោជន៍ឆ្ងាយ
ពាលាពុំចេះធម៌ទាំងឡាយ សង្សារវែងឆ្ងាយពីនិព្វាន ។

(៨)តិលមត្តំ បរេសំវ អប្បទោសញ្ច បស្សតិ
នាឡិកេរំ បិ សទោសំ ខលជាតោ ន បស្សតិ ។

បុគ្គលកើតកូនត្រកូលកាច អាចយល់ទោសគេប៉ុនល្ង
មិនយល់ទោសខ្លួនដែលធ្ងើមក៏ ករប៉ុនចាំផ្លូងឈោងមិនដល់ ។
(រឺ) បុគ្គលយល់ទោសអ្នកដទៃ តូចប៉ុនគ្រាប់ស្ពៃបូល្ងសក
ទោសខ្លួនប៉ុនដូងទាំងសម្បក វិបរិតៈគយគន់មិនយល់ ។

(៩) នត្តទោសំ បរេ ជញ្ញា, ជញ្ញា ទោសំ បរស្ស តុ
គុយ្ហេ កុម្មោវ អង្គានិ បរទោសញ្ច លក្ខយេ ។

មិនឲ្យអ្នកក្រៅដឹងទោសខ្លួន ទោសគេបំពួនកាចដឹងបាន
ទោសខ្លួនពួនលាក់ធ្វើហាក់គ្មាន ដូចកល់ជើងក្រានលាក់ក្បាលជើង ។

(១០) បណ្ឌិតស្ស បសំសាយ ទណ្ឌោ ពាលេន ទិយ្យតេ[១]
បណ្ឌិតោ បណ្ឌិតេនេវ វិណ្ណិតោវ សុវិណ្ណិតំ ។

អាជ្ញាគឺមហាពាលកំណាច ឲ្យផលអ្នកប្រាជ្ញដោយសរសើរ
បណ្ឌិតគឺប្រាជ្ញកបដំណើរ សរសើរដោយគុណការគាប់ចិត្ត ។

(១១) លុទ្ធំ អត្ថេន គណ្ហេយ្យ ថទ្ធំ អញ្ជលិកម្មុនា
ឆន្ទានុវត្តិយា មូឡ្ហំ យថាភូតេន បណ្ឌិតំ ។

ផ្គាប់អ្នកលោភដោយរកមិសត្រឹមគួរសម ផ្គាប់អ្នករឹងដោយប្រណម្យ
ដៃបណ្ឌិត

---

១. ធម្មនីតិយំ: “នីយតេ”តិ ទិស្សតិ ។

ផ្ចាញ់អ្នកមោហ៍ដោយប្រព្រឹត្តទៅតាមចិត្ត    ផ្ចាញ់អ្នកបណ្ឌិតដោយពោល
ពាក្យសត្យ ។

## ពាលទុជ្ជនកណ្ឌោ និដ្ឋិតោ

កណ្ឌនៃជនពាលកក្រក់ចប់តែប៉ុណ្ណេះ

គម្ពីរពាលទុជ្ជនកណ្ឌនេះ មានគាថា ១១ គាថា

## មិត្តកណ្ឌ ទី ៤

(១) ហិតការោ[១] បរោ ពន្ធុ ពន្ធុបិ អហិតោ បរោ
អហិតោ ទេហជោ ព្យាធិ ហិតមារញ្ញមោសធំ ។

*អ្នកដទៃធ្វើប្រយោជន៍ទុកជាញាតិ ញាតិបើឃ្លាតទុកជាជាតិអ្នកដទៃ*
*រោគក្នុងកាយទុកជាទោសប្រកបភ័យ ឈើក្នុងព្រៃជាឱសថទុកជាគុណ ។*

(២) បរោក្ខេ គុណឃាតោ យោ[២] បច្ចក្ខេ បិយភាណិនំ
វជ្ជេយ្យ តាទិសំ មិត្តំ វិសកុម្ភេ យថា មធុំ ។

*មិត្រឯណាលុបគុណមិត្រកំបាំង លុះបកតាំងត្រោះមុខពោលភិរម្យ*
*មិត្របែបនោះគួរតែកុំសេពគប់ ដូចទឹកឃ្មុំនៅក្នុងឆ្នាំងថ្នាំពិស ។*

(៣) សោ ពន្ធុ យោ ហិតេ យុត្តោ បិតា យោ ហោតិ បោសកោ
តំ មិត្តំ យត្ថ វិស្សាសោ សា ភរិយា យត្ថ និព្វុតិ ។

*ជនឯណាគប់គុណប្រយោជន៍បាន ជននោះហៅសន្តានញាតិវង្សផៅ*

---

១ បោរាណបោត្ថកេ ហិតការកោតិ ទិស្សតិ ។ ធម្មនីតិយំ បន ហិតករោ... ហិតមារញ្ញមោសធំតិ លិខិតា ។ ២ បោរាណបោត្ថកេ គុណហន្តារ ឥតិ ទិស្សតិ ។

(៨) ជនឯណាមាត់ក្រហូបដូចប្រទុម ពាក្យពិរោះដូចជាតិបទូន្ទែរជាក់
តែក្នុងពោះដូចពិសមុតដូចចក្រ ជននោះគួរកុំស៊ែស្មាគមឡើយ ។

(៩) ន សេវេ ផរុសំ សាមឹ ន ប សេវេយ្យ មច្ឆរឹ
តតោ អប្បគ្គណ្ហំ សាមឹ នេវ និគ្គហិតំ តតោ ។

កុំសេពម្ចាស់ក្រោតក្រោធជាតិប្រើញ កុំសេពម្ចាស់កំណាញ់កកាញ់ទុន
កុំសេពម្ចាស់មិនលើកដំកល់គុណ ។ កុំសេពម្ចាស់យកបុណ្យមកសង្កត់ ។
(៩) ម្ចាស់កំណាញ់ពេញកំណាចលើសម្ចាស់ក្រោធ ម្ចាស់ថយជាតិ
មិនលើកលើសម្ចាស់កំណាញ់

ម្ចាស់ផ្ចញ់ផ្ចាល់ដួលលើសមិនលើកវិញ ម្ចាស់៤នេះកុំស្រឡាញ់យកជា
ម្ចាស់ ។

(១០) សិង្គាលំ បញ្ញាសហត្ថេន សតេន រាជិតំ វជ្ជេ
ហត្ថិទន្តំ សហស្សេន ទេសបាតេន ទុជ្ជនំ ។

វៀរសត្វមានស្នែង៥០ហត្ថ វៀរសត្វសេះហត្ថ១រយក៏
វៀរដំរីមានភ្លុកពាន់ហត្ថ វៀរជនពាលចេញពាក់ស្រុក ។

(១១) កុទេសញ្ច កុមិត្តញ្ច កុកុលញ្ច កុពន្ធវំ
កុទារញ្ច កុទាសញ្ច ទូរតោ បរិវជ្ជយេ ។

ប្រទេសអាក្រក់មិត្រអាក្រក់ត្រកូលកាច ញាតិកំណាចប្រពន្ធគុំទុំទីរើស
គប្បីចៀសឲ្យឆ្ងាយចេញឲ្យរហ័ស ឬទៅបួសដើរផុតគន្លងទៅឲ្យបាត់ ។

(១២) រោគាតុរេ ច ទុព្ភិក្ខេ ព្យសនេ ច សត្តុគ្គហេ
រាជទ្វារេ សុសានេ ច សខា តិដ្ឋ សុមិត្តកា ។

សំឡាញ់ឯណាយកអាសាការពិនាក់ គ្រាកាលធ្លាក់កើតរោគគ្រុនរ៉ា
ឬស្រុកកើតទុព្ភិក្សវេទនា គ្រាត្រូវរន្ធត់ដោយទុក្ខភ័យ ។
គ្រាកាលសត្រូវចាប់ប្រហារ គ្រាទ្វារកោជាំងទៅវាំង
គ្រាស្លាប់បាននាទីខ្មោចព្រៃ សំឡាញ់យ៉ាងនេះនៃហៅសុមិត្ត ។

(១៣) សីតវាតោ ពហុមិត្តោ ផរុសោ បិ អមិត្តកោ
ឧបមំ ឯត្ថ ញាតព្វំ សុរិយោ ចន្ទរាជូនំ ។

វាចាត្រជាក់មិត្រជុំច្រើនទៅ វាចាក្តៅមិត្រក៏ឃ្លាតប្រាសចាកមិត្រ

ត្រជាក់ក្តៅដូចព្រះចន្ទនិងព្រះអាទិត្យ ហៃបណ្ឌិតគួរដឹងដោយឧបមា ។

## មិត្តកណ្ឌោ និដ្ឋិតោ

### មិត្តកណ្ឌចប់បរិបូណ៌

ក្នុងកណ្ឌនេះ មានគាថា១៣គាថា

## ឥត្ថីកណ្ឌទី ៥

(១) កោកិលានំ[១] សទ្ទំ រូបំ នារីវត្តំ បតិវត្តា[២]
វិជ្ជារូបំ អរូបានំ ខមា រូបតបស្សីនំ ។

សំឡេងតាវជារូបរ៉ា ប្រតិបត្តិភស្តាជារូបស្រី
វិជ្ជាការជារូបប្រុសកាឡី អត្តខន្តិជារូបនៃតាបស ។
(នៃ) នារីណាមានកាយពិការអគ្គ តែបេះដូងប្រតិបត្តិធ្វើវត្តប្តី
នារីនោះឈ្មោះថារូបពិសី ប្រុសកាឡីរូបពិការតែបេះការ ។
វិជ្ជាការបេះនោះនាំយោងប្រាណ ជួយឲ្យបានហានន្ទទើអាចារ្យ
បុស័ក្តិយសខ្ពង់ខ្ពស់គន្ធសន្ធារ មិនខាតការលោកិយស្រីគង់ដោយ ។

(២) ឥត្ថីធញ្ញ ធនំ រូបំ បុរិសានំ វិជ្ជា ធនំ
ភិក្ខូធញ្ញ ធនំ សីលំ រាជូធញ្ញ ធនំ ពលំ ។

រូបកាយនៃស្រីជារបស់ វិជ្ជានៃបុរសជាទ្រព្យ

---

១ - លោកនយេ បន៖ កោកិលានំ សរោ រូបំ. នារីរូបំ បតិព្វតា៖ វិជ្ជា រូបមរូបានំ ខន្តិរូបំ តបស្សីនន្តិ ទិស្សតិ ។ ២ ធម្មនីតិយម្បិ៖ នារីរូបំ បតិព្វតន្តិ វាយតិ ។

សីលនៃភិក្ខុសង្ឃជាសោភា | កំឡាំងនៃពលជាជាសោភា ។
(២) ស្រីមានរូបជាសម្បត្តិ | ប្រុសចាត់វិជ្ជាជាធនធាន
ភិក្ខុសង្ឃមានសីលជាទ្រព្យបាន | ក្សត្រក្សត្រមានពលជាសោភា ។

(៣) កីសា សោភាវិ តាបសា ថូលា សោភា ចតុប្បទា
បុរិសា ច វិជ្ជាសោភា ឥត្ថី សោភា សសាមិកា[១] ។

តាបសរូបស្គមនោះឧត្តម | ចតុប្បទធាត់ធំនោះសោភណា
ប្រុសមានវិជ្ជានោះសោភា | ស្រីមានភស្តានោះសោភី ។
(២) បុរសសោភ័ណដោយវិជ្ជា | ស្រីសោភាដោយស្វាមី
ចតុប្បទល្អដោយធំឥន្ទ្រិយ | ព្រះមុនីល្អដោយមានរូបស្គម ។

(៤) បញ្ចរត្តា សុគន្ធញ្ញា សត្តរត្តា ធនុគ្គហា
ឯកមាសា សុភរិយា អឌ្ឍមាសា សិស្សាមលា ។

របាំបង់លេងលង់៥ថ្ងៃ | ជាមន្ទិលគឺដៃខុសលំពេន
នាយខ្មាន់ធ្នូបង់បាញ់កន្លងបាន | ប្រាំពីរថ្ងៃក៏មានមន្ទិលភ្លាត់ ។

១- ពោកណាពោត្តកេះ ជគោ បរំ ច សត្តេ ទិស្សតិ ។

ប្រពន្ធល្អបង់ប្តីលង់១ខែ    ជាមន្ទិលគឺប្រែចិត្តប្រតិព័ទ្ធ
សិស្សបង់សិក្សាការគុំនិគ្ត    គង្វះខែកំភ្លាត់ការសិក្សា

## សុភាសិតបា :

ក្លាបង់ចាញ់ ធម៌បង់ចន្ទេញ ស្រីបង់កស្តា រទាំបង់លេង វង្វេងដក ចុះក្នុងមណា មន្ទិលសៅហ្មង ។

(៥) ហាំ.រមតិ បំ. ហាំ. រមតិ ពោ. ចឹ. រមតិ បុ. ខុ. រមតិ ធំ. ។

ក្របីត្រែកន្ទាច ហង់ព្រាដត្រែកស្រះ ស្រីម្នះត្រែកប្រុស ភិក្ខុត្រែកធម៌ ។

(៦) ជិណ្ណកមន្ទុំ បសំសេយ្យ ទារញ្ច គតយោព្វនំ ។
(១)
រណាព្រឹត្តាគតំ សុរំ សស្សញ្ច គេហមាគតំ ។

សរសើរថាយកាលថាយរលាយជាប    សរសើរប្រពន្ធកាលគាត លង់អជិក

សរសើរពលកាលវិលពាកប្រាបសឹក សរសើរស្រែកាលផឹតស្រូវយកផ្ទះ ។

---

១- ហោភណាយោឆ្លុកេ : រណប្រឹង្គាពាប់សុរំ ឥដិ ចិស្សុតិ ។

(៧) ទុដ្ឋិ[១] បតិនារី ច វិហារទុដ្ឋិ បតិភិក្ខុ
សកុណោ ទុដ្ឋិបាសញ្ច កតមាយា ពហុតរំ ។

នារីមានប្តីពីរបីដង    ភិក្ខុផងនៅវត្តពីរបីរ៉ា
បក្សីជាប់ផង់ពីរបីគ្រា    មាយាពួកនេះធ្វើច្រើនក្រៃ ៗ

បុរាណគតិហ:

ពុកសិស្សគ្រូបី    ពុកស្រីប្តីលែង    ពុកគោផ្តែលែង    ពុកឆ្កែបង់ម្ចាស់ ៗ

(៨) ទុជ្ជនំ បហារ ទន្តិ មិត្តំ ទន្តិ អភណិកា
ទុត្តិនំ ព្យសនា ទន្តិ រាគីនំ អប្បភោជនា ៗ

រម្ងាប់ជនកំណាចដោយប្រហារ    រម្ងាប់មិត្រពាលដោយកុំស្តី
រម្ងាប់ស្រីដោយកុំឲ្យស៊ីៗ    រម្ងាប់រោគដោយតិចនូវបាយ ៗ
(ឬ) ជនខូចទាញ់ប្រហារ    មិត្រសាមាជិទាញ់កុំព្រាជ្ញ
ស្រីកំណាចទាញ់កំណាញ់    រោគាគាញ់ទាញ់បាយតិច ៗ

---

១ - គត្ថ ទុដ្ឋិ ឥតិ ហយតិ ។

(៩) រត្តិ ហីនា ន ចន្ទិមា វីចិហីនា ន អណ្ណវា

ហង្សហីនា ពោក្ខរណី បតិនា កញ្ញា ន សោភតេ ។

រាត្រីវៀរព្រះចន្ទមិនសោភា សាគរវៀររលកមិនសោភី

ពោក្ខរណីវៀរហង្សពុំពិសី នាងកញ្ញាវៀរប្ដីពុំពិសេស ។

(រៃ) រាត្រីពុំមានព្រះចន្ទ្រា មេឃោងងឹតឥតរស្មី

សមុទ្រឥតរលកបោកប្រក្រតី រលំស្ងៀមស្ងាត់បាត់ខ្សូរខ្សារ ។

ស្រះស្រង់ឥតហង្សបុះពារ ជាទីប្រៀបដូចឥតបរិពារ

កញ្ញាឥតប្ដីគ្រងព្យាបាល ករការនាំកើតឲ្យគេកៀវ ។

(១០) បតិនា ជនិតំ ភោគំ ឥត្ថិយា វិ សុគុត្តគំ

បុរិសោ វិហិ បជាតោ ឥត្ថី សូបិ សុត្តំ យថា ។

ទ្រព្យសម្បត្តិគីប្ដីឲ្យកើតមាន ស្រីជាពានទទួលគ្រងរក្សា

បុរសជាប្រធាននៃគរយោ ស្រីដូចជាចេះបម្ពុលផុលជាប់នៅ ។

(១១) សព្ពូ នទី វង្កគតិ សព្ពេ កដ្ឋមយា វនា

សព្ពិត្ថិយោ ករេ បាបំ លភមានា និវាតកេ ។

ស៊ីនតាំងឲ្យមានខែទ្រទឹកវៀចវ៉ក្ត    ព្រសឹងដំហើយដោយឈើផង
ស្រីបានទទួលសស្លាត់ជាមួន    អាចកន្ទុងធ្វើបាបកូនទីស្លាត់ ។

គាថានេះឈ្មោះឥន្ទវជិរឆន្ទ

(១២) វិវាទសីលី ច ឧស្សុយ្យភាណី(១)
បសន្នគណ្ហី ពហុបាកកីណី
អត្តនភត្តី បរគេហវាសី
នារី ច តា បុត្តសតំ បិ បុមា ។

ស្រីឯណាមានប្រែក្រតីពោលវ៉ាច    មានប្រែមាត់ពោលនាំពាក្យប្រុស្រ
គ្រែកបិណាងឲ្យប្រែសគន់កក្ដា    កិរិយាស្វាំប្រែតាំប្ដី ។
ស៊ីបាយមុនប្ដីនៃកក្ដា    គេពយាគ្រាផ្ទះគេពុំផ្អក
ស្រីយ៉ាងនេះបុរសគ្រូលោកិយ    ពោះអោនកូនចរយក្ដិគប្បីលែង ។

(៤ខ) នារីផ្អូជាតិ បង្កវ៉ាច បង្កិនឲ្យវាច ប្រែការអំនួត ប្រែគួរអំណាច ប្រែកំរិតូជកាច ប្រែការនពង្ក ៗ ដាំស្វេះខ្លាយ បង់ខាត

---

១- បោរាណបោត្ថកេ, ឧស្សុយ្យ ភាណិនីតិ ចាហេ អាគតោ ។

មិនស្តាយ មិនស្តាប់បេបា ឃើញប្រុសក្រឡេក ដំរេកតណ្ហា · សំដែងមាយា មារយាទកំបុកល ។ បរិភោគចំណី បំពុលស្វាមី មិនទុកសំភាល់ រូបខ្មាយចុះក្រែស សំណោះទៅដល់ ផ្ទះគេថ្ងៃងកល ថ្ងៃងកិច្ចការកម្លាយ ។ ប្រុសប្រាជ្ញក្រែកក្រិះ បើបានស្រីនេះ ព្រះស្តែងកុំស្តាយ ក្រហល់ស្ដីនៅ យូរទៅក្រោយ នោះកូនយេជាយ គួរខ្ពស់ផាចិ · ។

គាថានេះឈ្មោះវង្សដ្ឋ ១២ ក្ខ ១ បាទ

(១៣) ភុត្តេសុ មុព្ភេសុ ជរំ វ រក្ខតិ
គុយ្ហេ ច ប៉ាតេ[១] ភគិនីវ អាហរិ
កម្មេសុ ភត្តេសុ ករី វ ទាសិនី
ភយេសុ មន្តី សយនេសុ ភាមិនី
រូបេសុ សិក្ខី កុបនេសុ ខមិនី

១ · បោរាណបោត្ថកេ : ‹ គុយ្ហេសុ ហាមេសូតិ ទិស្សតិ ។

## សា ធារី សេដ្ឋិ វុឌ្ឍិ បណ្ឌិតា
## កាយស្សភេទា(១) តិទិវេ ភរិយា សា ។

ស្រីឯណា សុចរិតចិត្តភក្តី ញាំងស្វាមីឲ្យត្រេកក្នុងកិច្ចការ
តាំងពីកាលបរិភោគនូវអាហារ ឬក្នុងការប្រដាប់សំពត់ប្រាណ ។
ស្រីយ៉ាងនេះលោកប្រៀបដូចជននី ព្រោះជាទីញាំងបុត្រឲ្យក្សេមក្សាន្ត
ស្រីឯណា មានខ្មាសក្នុងស្ថាន ការកំបាំងមិនបានបែកប្រែប្រាយ ។
ស្រីយ៉ាងនេះលោកប្រៀបដូចប្អូនស្រី ព្រោះប្ដីបាំងហេតុផងទាំងឡាយ
ស្រីឯណាគោរពការសម្លាយ ប្រតិបត្តិដូចនាយទៅហ្វាយពិត ។
ស្រីយ៉ាងនេះលោកប្រៀបដូចទាសី ព្រោះប្ដីតាត់ការដប្រចិត្ត
តាំងក្រោកការភ័យព្រួយឲ្យជិត ចូលសព្ភិតខាងក្រោនវិនស្វាមី ។
តាំងមានវត្តប្រតិបត្តិឲ្យដាប្រែក ក្នុងកាលត្រេកនិទ្រាជាប្រក្រតី
គាត់តែងកាយប្រកបការមេត្រី ទាំងអំណត់អត់ទន្តិត្របក្រោធបាន ។
អ្នកប្រាជ្ញផងពោលថាស្រីព្រួតនោះ ចុះក្នុងឈ្មោះប្រសើរក្រៃសុគាន

១- អដ្ឋ បរច្ឆេទ ១យ៉ែ ។

ស្រីពួកនោះលុះក្ស័យប្រល័យប្រាណ បានទៅកើតក្នុងស្ថានទេពត្រៃ
ត្រឹង្ស ។

គាថានេះឈ្មោះឥន្ទវជិរឆន្ទ ដែលក្នុង ចតុត្ថបាទ ជាឆន្ទផ្សេង

(១៤) សាមាមិគត្តី តនុមជ្ឈគត្តា
គម្ភីរនាភី យុវតី សុសីលី
ស្សុរំ សុកេសី សមបណ្ណិទត្តី
ហីនកុលេ ជាតិ បិ សា វិរោហេ ។

ស្រីក្រុំឯណាគប្បូបរាង សព្វសពាង្គល្មៀងដូចសុវណ្ណ
នេត្រថ្លាយធំដូចក្នុងផ្កាក្រម៉ឹត បត្តឹះរៀវស៊មស្នាកាងកងកជហង្ស ។
ម្ល្រស្រលចំខ្លួលសមគោ ហាងកេសាខ្មៅយង់ចុងង់ខ្វង់
ធ្មេញចន្លាត្រឹមល្អស្រលង់ គាក៏ចែង់ខ្វង់ផ្ដៅកបហារយាច ។
ស្រីមានលក្ខណៈល្អយ៉ាងនេះ ទាំងចំណោះបេះគារបម្រុងញាតិ
ទោះបីកើតក្នុងត្រកូលហីនជាតិ គួរសង្វាតអភិសេកឯកមហេសី ។

(១៥) សរទំ[១] ឧតុកាលាធំ ភរិយាធំ រូបវតី

១· លោកណាថោះគេ : សរទំ ឧតុកាលភគ្គិ ទីសបូតិ ។

ជេដ្ឋោ បធានោ[១] បុត្តានំ ទិសានំ ឧត្តរំ ទិសំ[២] ។

ខែកត្តិកជាប្រធានរដូវកាល រូបវិសាលជាប្រធានស្ត្រីភរិយា
បុត្រច្បងជាប្រធានបុត្រនានា ទិសឧត្តរជាប្រធានទិសទាំងពួង ។

(១៦) យា ឥច្ឆេ បុរិសំ នារី ជាតិជាតិបុនប្បុនំ
សាមិកំ អបចាយេយ្យ ឥន្ទំ វ បរិចារិកា ។

នារីឯណាប្រាថ្នាបុរសគាប់ ចង់ជាប់រឿយៗសព្វជាតិណា
គួរគោរពស្វាមីនៃអាត្មា ដូចអប្សរាបំរើព្រះកោសិយ ។

(១៧) យោ ឥច្ឆេ បុរិសំ ហោសោ ជាតិជាតិបុនប្បុនំ
បរទារំ វិវជ្ជេយ្យ ធោតបាទោ វ កទ្ទមំ ។

បុរសឯណាប្រាថ្នាជាប្រុសនោះ សព្វៗជាតិលុះគ្រាន់ទៀង
គួរវៀរប្រពន្ធគេឲ្យបាន ដូចជើងវៀរស្អាតពុកផុងផង ។

(ខែ) ចង់បានប្រាណជាប្រុសឲ្យតាំងទៀង វៀងៗកល់ជាតិប្រុសនេះហើយ

---

១· ពត្ថ ជេដ្ឋប្រធានំ បុត្តានម្ពិ ឯយតិ ។ ២ ពត្ថ ទិសានំ ឧត្តរំ ប្រធានម្ពិ បាឋោ អាគតោ។

គួរទៀប្រៀបពន្លកដទៃ    ទិសស្រយការបង់នីវប្រគេង ។

(១៨) អតិមហល្លកោ បោសោ អានេសិ តិម្ពរុត្ថនឹ

តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។

បុរសចាស់បាននូវនាងក្រមុំ    ដោះពកឡើងកំប៉ុនចន្ទាប់

សឹងវិលតាមអំណាចនាងនោះជាប់    ការនោះគប់ជាហេតុអន្តរាន ។

(វិ១) ចាស់ទើកបាននូវនូវក្រមុំ    ដោះកំព្រកប៉ុនផ្លែទន្ទ្រាប់

សែនស្រឡាញ់ពេញចិត្តប្រព្រឹត្តជាប់    របស់អ្វីក៏ផ្តាប់ក៏ចាំងអស់ ។

ហើយទៀតកាលណាក៏ឲ្យក្រោម    ស្ងប់ព្យាយាមអន្ទ្រលចន្ទាប់ស្រស់

សុំពុំបានកំសូហិតតែរស    ការចាំងអស់ជាហេតុបកមុខ ។

ឥត្ថីកណ្ឌោ និដ្ឋិតោ

កណ្ឌនៃស្ត្រី ចប់បរិបូណ៌

ក្នុងកណ្ឌនេះមានគាថា ១៨ គាថា

## រាជកណ្ឌទី ៦

(១) ឯកយាមំ សយេ រាជា ទ្វិយាមញ្ចេវ បណ្ឌិតោ
ឃរាវាសោ តិយាមោវ ចតុយាមោ តុ យាចកោ ។

ស្តេចផ្ទំអស់យាម១ជានិត្យ បណ្ឌិតដេកអស់យាមពីរជាក់
គ្រហស្ថដេកអស់យាម៣ភ្ញាក់ ពួកយាចកដេកលក់អស់យាម៤ ។

(២) ធនវា សុតិយោ រាជា នទី វេជ្ជោ តថា ឥមេ
បញ្ច យត្ថ ន វិជ្ជន្តិ ន តត្ថ ទិវសំ វសេ ។

អ្នកមានសម្បត្តិទី១អ្នកប្រាជ្ញ ទី២ស្តេចគ្រប់គ្រងទី៣ព្រែកស្ទឹង
ទី៤ពេទ្យវេទ្យជាទីពឹង ប្រាំនេះសូន្យលើដែនស្ថានណា ។
ស្ថាននោះមិនគួរនៅក្រប័យ ជាស្ថានចង្រៃឥតសុខា
កំណត់ថ្ងៃមួយៗវេលា កុំនៅចំយាគ្រាពេញផុត ។

(៣) យស្មិំ បទេសេ ន មានោ ន បេមំ ន ច ពន្ធវា
ន ច វិជ្ជាគមោ កោចិ តត្រ ទិវសំ ន វសេ[១] ។

---

១៖ អយំ គាថា តត្ថ លោកនយោត្តកេ ន ទិស្សតិ ។ អតិរេកេន បញ្ញា ភវិតព្វំ ។

ក្តីរាប់អានក្តីសំទុព្វាញ់ស្នេហា    ញាតិកាផៅពង្សវង្សត្រកូន
រកមានចំណេះចេះវេទមន្តក្រូន    ឯណាមួយនេះគ្មានគុណស្រុកណា ។
ស្រុកនោះឯងមិនគួរអាស្រ័យនៅ    ព្រោះនាំក្តីក្តៅក្តៅខ្លោចកា
គួរលះបោលចេញទៅរកស្រុកណា ដែលមានគុណាយ៉ាងថានេះគួរនៅ ។

(៤) អបុត្តកំ ឃរំ សុញ្ញំ រដ្ឋំ សុញ្ញំ អរាជិកំ
អសប្បុរិស្ស មុខំ សុញ្ញំ សព្វសុញ្ញំ ទលិទ្ទកំ ។

ផ្ទះឥតកូនសូន្យស្ងាត់    ដែនឥតក្សត្រសូន្យរកជា
មាត់ឥតសីលសូន្យវាចា    ទុគ៌តក្រសូន្យទាំងអស់ ។

(ខ) ផ្ទះឯណាឥតកូនផ្ទះនោះស្ងាត់ ដែនដែលឥតក្សត្រសូន្យរកជា
មាត់អ្នកឥតសីលសោស្រ្តសូន្យចរចា ទុគ៌តទ្រព្យសូន្យទាំងអស់ ។

(៥) ធនមិច្ឆេ វណិជ្ជេយ្យ វិជ្ជមិច្ឆេ ភជេ សុតំ
បុត្តមិច្ឆេ ឥណកតំ ភរិយមិច្ឆេ ឥច្ឆាគមេ ។

ប្រាថ្នាទ្រព្យគប្បីជួញសព្វនានា    ប្រាថ្នាវិជ្ជាគប្បីគប់បណ្ឌិតជាតិ
ប្រាថ្នាកូនគប់បេសាវក្សាតា    ប្រាថ្នាភរិយាគប្បីជាប់ចិត្តម្ចាស់ ។

(៦) ឆព្វោ យតំ អសព្វព្វោ សព្វព្វោ ប មហាបតិ

នដ្ឋា លជ្ជា គណិកាប កុលធីតា[1] បនិលជ្ជា ។

កាត់គតិ : សង្វេគសន្តោស   ករជាមានព្រោស សំនោសពោសា
សំផឹងទ្វាសប្រុស សន្តោសតៃយក មានកុលធីតា ឥតការគ្រូវាស ។
ជនបួនខេះមាន ឈ្មោះអន្តរាន ចុះហៅវិនាស នាក់ផ្សែលោកិយ. សិរី-
ទុកាស ពុំមានទុកាស បំរើនលោកិយ ។

(៣) បក្ខីនំ ពលមាកាសោ មច្ឆានមុទកំ ពលំ
ទុព្វលស្ស ពលំ រាជា កុមារានំ រោទនំ ពលំ ។

អាកាសជាកំឡាំងនៃបក្សា   គង្គាជាកំឡាំងត្រីខ្លៅត្រី
ករជាជាកំឡាំងនៃអ្នកក្រៀមក្រំ   ក្តីសោកយំជាកំឡាំងនៃកុមារ ។
(ខ) បក្សីសឹងរាងអាកាសស្ថាន ត្រីប៉ុន្មានសឹងរាងព្រះគង្គា
អ្នកទុព្វលសឹងរាងព្រះរាជា   តារកាតូចៗសឹងរាងយំ ។

បុរាណគតិថា.:

តាស់អាងស្លាប់ ពាលអាងប្រកាច់ កូនក្មេងអាងយំ ។

១ - បោរាណបោត្ថកេ : និលជ្ជា កុលធីតាតិ ទិស្សតិ ។

(៨) ឥមា ពាតវីសត្យាធិ សព្វភាគោ ទយក្ខតា

ឆាយកស្ស គុណា ឯតេ ពិប្បិតត្វា(១) សតំ គុណា ៗ

គុណភាព២ប្រមួយពីរពេកពាក់   ពីរគីគ្កាក់ហាកនិព្រោ
៣ គឺព្រោះគេឡើងដល់យម្ហា   ប្អូនគឺសុត្តាបេះពាត់បៃផ   ៗ
ព្រាំគឺតរុណភាពពាទន៍   ៦គឺគយគនះបើលទ្យៀស្តើរ
គុណាវាចាំ២បទនេះងណ៍   សើនតែពីពាទជល់លោកជានាយ   ៗ
នាយកសប្បុរេបត្តុរស្នេហា   ព្រាំពាំគុណភានេះទុកគុំនឹកាយ
ដើមជនចទ់ពាបរើនិទាំងឡាយ   ប៉ូលបកធ្វើកាយជីវិតផង   ៗ

(៩) យេកិ វិទត្ថ រាជាណោ សព្វេ សមណព្រាហ្មណា

សព្វេ សប្បុរិសា លោកេ ឯស ធម្មោ សនន្តនោ ៗ

បហាក្សត្រិយ៍កស់ព្រាស់តែប្អូន   សមណព្រាហ្មណ៍ផងពោលប្អូនស្រែច
សប្បុរសលោកសប្អូនពីកិសស្រែច   កម្មផលង៉ាច់ទុះជាធម៌បុរាណ   ៗ

---

១· [illegible]

(១០) អលសោ គិហី កាមភោគី សាធុ
អសញ្ញតោ បព្វជិតោ ន សាធុ
រាជា អនិសម្មការី ន សាធុ
បណ្ឌិតោ កោធនោ តម្បិ ន សាធុ ។

គ្រហស្ថបរិភោគកាមគុណ   ក៏ដែលស៊ិនហៅថាពុំប្រពៃ
បព្វជិតឥតសង្រួមក្នុងវិន័យ   មិនជាវិស័យក្នុងសាសនា ។
មហាក្សត្រតាត់ការធ្វើអ្វីៗ   មិនមានក្តីគិតមុនដោយបញ្ញា
ប្រាជ្ញបណ្ឌិតប្រព្រឹត្តក្រេវក្រោធ   ការនោះជាប្រពៃទៅពុំបាន ។

(១១) អាយាវយំ ជញ្ញា រាជា សយំ ជញ្ញា កតាកតំ
និគ្គហេ និគ្គហារហំ បគ្គហេ បគ្គហារហំ ។

មហាក្សត្រត្រូវជ្រាបព្រះរាជទ្រព្យ   វិនាសទៅឬត្រឡប់ចំរើនវិញ
ទាំងមានការឥតការហើយណាមិញ   គួរបំពេញឬបន្ទយដោយកិច្ចណា ។
អ្នកឯណាធ្វើខុសប្រោសធ្វើទោស   កុំសន្តោសយល់មុខសេវកា
អ្នកឯណាធ្វើត្រូវប្រោសមេត្តា   ជំកល់លើកសក្តាតាមក្តីគាប់ ។

(១២) បណ្ឌិតោ ភត្តំ[១] ន សេវេយ្យ កុដ្ឋិនា វិហុតាសនំ
សាមិកំ សត្រូភាគេន  បរលោកំ អមោហរា ។

ចូលជិតព្រះអាទិត្យដោយខាងខ្នង  ចូលជិតភ្លើងអគ្គីដោយខាងពោះ
ចូលជិតម្ចាស់ដោយគោរពភាគបន្ទោះ  ចូលជិតគ្រោះបរលោកដោយឥតមោហ៍ ។

បុរាណគាថា :

កាំងភ្លើងឲ្យកាំងពីខាងផ្ទៃ  កាំងថ្ងៃឲ្យកាំងពីខាងខ្នង ។

បើប្រែឲ្យគាត់បទថា បណ្ឌិតោ ភត្តំ; ក្នុងបាលីខ្វះថា បណ្ឌិតោ សូរិយំ សេវេ ឯកបិដ្ឋិតោ; ក្នុងតតិយបាទថា សាមិកំ សភាវេន ក្នុងចតុត្ថបាទថា បរលោកំ អមោហាយ "ជាគុំហទហយា" ។

(១៣) ទុដ្ឋភរិយាហិ សំវាសោ ទោសោ បិត្តទោសកោ
សសប្បេ ច ឃរេ វាសោ មច្ចុ ឯវ ន សំសយោ ។

---

១- ពោភណពោត្ថកេះ បណ្ឌិតោ វត្តុ និសេវេយ្យាតិ ទិស្សតិ ។

(១៧) អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
កទរិយញ្ច ទានេន សច្ចេនាលិកវាទិនំ ។

ឈ្នះអ្នកក្រោធដោយចិត្តមិនក្រោធតប ឈ្នះអសប្បុរសប្រកបដោយសប្បុរស ឈ្នះកំណាញ់ដោយឲ្យទ្រព្យរបស់ ឈ្នះបុរសទ្បេះទ្បាះដោយពាក្យសត្យ ។

(១៨) អទន្តំ មទនំ ទានំ.. ទានំ សព្វត្ថ សាធកំ
ទានេន បិយវាចាយ ឧន្នមន្តិ នមន្តិ ច ។

ទានជាទីញ៉ាំងជនដ៏មិនទន្ត ឲ្យលះបង់ពុតត្បុះកំណាចក្រាណ ទានកេបនាំប្រយោជន៍ទាំងពួងបាន បន្ទោនប្រាណពាក្យពិរោះក្រោះទាននាំ ។

(១៩) ទានំ សិនេហភេសជ្ជំ; មច្ឆេរំ ទោសនោសថំ
ទានំ យសស្ស ភេសជ្ជំ មច្ឆេរំ កប្បនោសថំ ។

ទានជាថ្នាំនាំកើតក្តីស្នេហា   កំណាញ់ជាគុលថនៃទោសទុក្ខ
ទានជាថ្នាំយសសក្តិចំរើនសុខ   កំណាញ់ទុកជាថ្នាំនាំកំព្រា ។

(២០) ពហូនំ អប្បសារានំ សាមគ្គិយា ជយាជយេ
តិណេន យោត្តំ វត្តេ តេន នាគោ បិ ពន្ធតិ ។

ជនប្រុសពាលគុណកម្មតាច្រើន   តែងចំរើនដោយក្តីសាមគ្គី
អាចផ្ចាញ់បានទូវពួកនៃពារី   ដោយឫទ្ធិសាមគ្គីដ៏ហោហាន ។
ខ្សែព្រួតគឺបុគ្គលវេញដោយស្មៅ   នាំយកទៅចងដំរីបាន
រូបតូចពិតតែចិត្តស្មើគ្រប់ស្មើប្រាណ   គង់ផ្ចាញ់បានរូបធំលើសអើយ ។

(២១) សហាយោ អសមត្ថោបិ[១] តេជសា កិំ ករិស្សតិ
និវាតេ បតិតោ អគ្គិ   សយមេវូបសម្មតិ ។

ស្តេចមានពលច្រើនជាអំណាច   តែពុំអាចទីផ្ចាល់ផ្ចាញ់សត្រូវ
ទីទីធ្វើអ្វីដោយគេជះកំដៅ   ដូចភ្លើងធ្លាក់ក្នុងរណ្តៅរលត់ឯង ។

---

១ បោរាណពោត្ថកេ បិ សទ្ទោ នត្ថិ ។

(២២) ន រញ្ញោ សមកំ ភុញ្ជេ កាមភោគំ កុទាចនំ
អាកប្បំ សរកុត្តិំ វា មាលាគន្ធវិលេបនំ
វត្ថំ សព្វមលង្ការំ ន រញ្ញោ សទិសំ ករេ ។

អ្នកសេវកាមាត្យប្រុលផ្គាប់បុណ្យ កុំបរិភោគកាមគុណស្មើក្សត្រា
កុំតប្រៀធ្វើអាកប្បកិរិយា ពោលកំចាត់តែងកោងមិនកោតក្រែង ។
កុំលាបគ្រឿងសុគន្ធពាក់មាលា ស្លៀកក្បូសាអគ្គាឲ្យលើសលែង
កុំសំអាងយ៉ាងយសព្រះតម្លង [illegible] អញ្ជើញតែងឲ្យសមសភាពខ្លួន ។

(២៣) ន មេ រាជា សខា ហោតិ ន រាជា ហោតិ មេថុនោ
ឯសោ សាមិកោ មយ្ហន្តិ ចិត្តេ និដ្ឋំ សុដ្ឋបេយ្យ ។

រាជអាមាត្យគួរគិតក្នុងចិត្តថា៖ ថាព្រះរាជានេះមិនមែនជាមិត្រស្និទ្ធ
មិនមែនជាញាតិសាច់សាលោហិត ព្រះអង្គពិតជាម្ចាស់នៃអាត្មា ។

---

(២៤) នាតិទូរេ ភជេ រញ្ញោ នច្ចាសន្នេ បវាតកេ
ឧជុកេ នាតិនិន្នេ ច ន ភជេ ឧច្ចមាសនេ

ឆ ទោសេ វជ្ជេ សេវកោ អត្ថិ វ សំយតោ តិជ្ជេ ។

សេវកាមាត្យចូលគាល់មហាក្សត្រក្សត្រា គួរវៀរទោស៦ស្ថានប្រយ័ត្នកិរិយា

១ កុំគាល់ឆ្ងាយពេកប៉ាន់ទេត្រា   ២ កុំគាល់ជិតខាំនាំងក.សទ ។

៣ កុំគាល់លើខ្យល់ពាល់ព្រះអង្គ   ៤ កុំគាល់ខ្ពោះត្រង់ព្រះភក្ត្រម្ចាស់ ។

៥ កុំគាល់លើទួលឬទាបណាស់   ៦ កុំខ្ពស់អាសន៍លើម្ចាស់គង់ ។

កាលចូលគាល់សន្ធឹមកាយតាមសក្តិ ហេតុយក្ខាក់ជាក់ខ្លួនឲ្យសមម្រង់

ដូចអ្នកចូលជិតភ្លើងកុំភ្លេស្ព   តែភ្លេចកាយភ្លើងឆេះលោកប្រាណ ។

## (២៥) គុណោ សព្វញ្ញុតល្បេបិ ឆ សោភតិ អនិស្សយោ[១]

## អនគ្ឃម្បិ មណិកំ   ហេមំ និស្សាយ សោភតេ ។

អ្នកមានគុណវិជ្ជាខេះលើសលប់   បញ្ញាស្មើមកពសព្វញ្ញុតញ្ញាណ

តែគ្មានលោកជាធំធំរកប់កាន   លើកដំកល់កន្លែងស្ថានពុំបានល្អ ។

ដែរមណីយ៉ាងថ្លៃថ្លាគាត់ពុំបាន   កស្រស់យ៉ាងមាសជាស្ថានជាផ្ទះនៅ

ទើបមណីរុងរឿងរៀងលើរ   ប្រើផ្តតមាសទីន្ទែល្អម្តេចខ្ញុំ? ។

១· លោកណលោកេ· ឥតោ បរ មិលក្ខេ អត្ថិ ។

# រាជកណ្ឌោ និដ្ឋិតោ

សំដែងមកក្នុងកណ្ឌនៃស្តេចក៏ចប់បរិបូណ៌

ក្នុងកណ្ឌនេះមានគាថា ៤៥ គាថា

## បកិណ្ណកកណ្ឌទី ៧

(១) ឥត្ថិមិស្សេ កុតោ សីលំ មំសភក្ខោ កុតោ ទយំ
សុរាបានោ កុតោ សច្ចំ មហាលោភោ កុតោ លជ្ជ
មហាគន្ថោ កុតោ សិប្បំ មហាកោធោ កុតោ ធនំ ។

ភិក្ខុសង៍ប្រឡូកដោយស្រីកា    សីលសិក្ខាមានពីណាបរិសុទ្ធ
អ្នកស៊ីសាច់មានពីណាចិត្តលំអុត ប្រមឹកស្រាមានពីណាពោលពាក្យសត្យ ។
មហាលោភមានពីណាក្តីខ្មាសអៀន    អ្នកខ្ជិលរៀនមានពីណាសិល្ប
សាស្ត្រស្ទាត់
មហាក្រោធមានពីណាទ្រព្យសម្បត្តិ ឥតប្រតិបត្តិមានពីណាបញ្ញាបុណ្យ ។

ច្បាប់ក្រមហៈ

បញ្ញាបុណ្យផង    កើតដោយប្រតិបត្តិ ។

~~(២) សុភយោគោ វិកាលោ ច សមជ្ជបរណង្គតោ~~
ទិដ្ឋរតោ[១] បាបមិត្តោ ភោគានំ អលស្សំ មុខំ ។

---

១· អញ្ញត្ថលោកតោៈ ទិដ្ឋរតោ៖ ពោះក្បៀត ទិស្សតី ។

ហេតុវិនាសសម្បត្តិ ៦ យ៉ាង ។ មួយបានខាងប្រមឹកផឹកសុរា
ពីរគឺដើរត្រាច់លេងខុសវេលា បីគឺយាត្រាមើលរាំរបាំភ្លេង ។
បួនគឺលេងល្បែងភ្នាល់ពេញពិត ប្រាំគឺគប់បាបមិត្រមិត្តអ្នកលេង
៦ គឺកំជិលមិនចាត់ចែង ពួកនេះឯងប្រយោជន៍អន្តរធាន ។

(៣) ជីវត្តា បំ មតា បញ្ច ព្យាសនេ បរិកិត្តិតា[1]
ទុក្ខិតោ ព្យាធិតោ មូឡ្ហោ ឥណវានិត្យាសេវកោ ។

មនុស្សរស់ឈ្មោះស្លាប់មានប្រាំហេតុ មួយគឺពេទ្យបំរាបខ្មោចបិសាច
២ គឺកើតព្យាធិពេកកំណាច បៀតបៀនកាយមិនអាចឲ្យក្សាន្តចិត្ត ។
៣ គឺអ្នកមូឡ្ហកំជិលជាក់ ៤ គឺអ្នកជំពាក់បំណុលពិត
៥ គឺរាជអាមាត្យគាល់នៅទិត្យ មានជីវិតប្រាំនេះប្រាជ្ញថាស្លាប់ ។

(៤) អនាគតំ ភយំ ទិស្វា ទូរតោ បរិវជ្ជយេ
អាគតញ្ច[2] ភយំ ទិស្វា អភីតោ ហោតិ បណ្ឌិតោ ។

---

១- ព្រាហ្មណបោត្ថកេះ បរិកិត្តិតាតិ ទិស្សតិ ។ ២- តត្ថ ប សត្ថា ឥតិ ។

អ្នកប្រាជ្ញឃើញភ័យពុំទាន់ដល់ យោបល់គិតវៀរពីចម្ងាយ
លុះកាលឃើញភ័យមកដល់កាយ មុខនៅប៉ប្រាយឥតគិតភ័យ ។

(៥) ឆិទ្ទាលុកោ បមាទោ ច សុខិតោ រោគភៈលស្យោ
តិប្បន្តោ កម្មារាមោ ច សត្តេ តេ សត្តវជ្ជិតា ។

មនុស្សវៀរផែ្ម៉ា ៧ នាក់ មួយគឺអ្នកលោភដេកត្រេកទិវា
ពីរគឺអ្នកប្រមាទសព្វវេលា បីគឺអ្នកសុខាភ្លេស្មារតិ ។
បួនគឺអ្នកមានរោគជាមន្ទិល ប្រាំគឺអ្នកកំជិលជួរប្រើយ
៦ គឺប្រាថ្នាការលោកិយ ៧ គឺមានក្តីត្រេកក្នុងការ ។

(៦) ទុគ្គតំ គច្ឆ ហេ លាភ លាភោ លាភេន បូរតិ
បិលេវិសត្ត្រំ បច្ចន្ន អាបោ អាបេន បូរតិ ឆត្តិទំ កម្មប្រជានំ ។

កាកគតិ: ម្នាលទៅលាភា ចូរប្រាម្នា ទៅកាន់ទុគត លាភតែពេញកប់
ដោយហេតុប្រាកដ មិនមានកំណត់ កំណើតលាភា ។

---

បពិត្របងប្អូន ស្តេចជាទៀន ក្អាក់ក៏ររក្យ អញ្ចើញបញ្ជូរ បង្អួរ-

ក្អែក ធ្លាក់ចុះក្នុងនា ទីទួលបព្វស្ថាន ។
ទីពេញដោយទឹក ជន់ជោរពន្លឹក ទៅតាមលំអាន បទនេះបួលចិត្ត
ប្រព្រឹត្តទៅបាន ជាកម្មប្រធាន ពុំមានឡើយហោង ។

## សុភាសិតបិៈ

ទឹកធ្លាក់ទៅទាប លាភធ្លាក់ទៅសិរី ខ្ទួលហៅម្តេចក្តី ទឹកទៅពុំបាន ។

(៧) នហិ កោចិ កតេ កិច្ចេ កត្តារំ សមុបេក្ខតេ
តស្មា សព្វានិ កិច្ចានិ សាវសេសេន ការយេ ។

នាកាលកិច្ចការគេទូនធ្វើហើយ គ្មាននរណាមួយឡើយមើលនរណា
ហេតុនោះឯងកិច្ចការសព្វអំពើ ពោះជាធ្វើការនោះដោយសល់នៅ ។

(៨) តុលំ សល្លហុកំ លោកេ តតោ បិប្បលជាតកោ
តតោ វុឌ្ឍមនោ ភិទោ បមាទោ ពុទ្ធសាសនេ ។

ប៉ុយគរសំឡីជាជាតិស្រាល មនុស្សពាលក្អៀកក្អាស្រាលលើសទៅក្រៃ
មនុស្សបង់ឥតខ្លាសប៉ុន្មាន ស្រាលលើសជាងទៅក្រៃនានា ។
មនុស្សប្រមាទប្រមាថនៅសព្វកាល លោកថាត់ហៅស្រាលក្នុងសាសនា

ប្រហាចមាននៅលើអ្នកណា　　អ្នកនោះបុះត្រាមចុកជ ។

(៩) បាសាណឆត្តំ គរុកំ តតោ ទេវាទាបិក្ខនំ
តតោ វិឡ្យន់មោវិទោ តតោ ពុទ្ធស្ស វិបនំ ។

ឆត្រថ្មថាថាជាតិធ្ងន់　　បិក្ខុទេពអត់ធន់ធ្ងន់មហិមា
អ្នកតាមតពចចាស់ព្រឹក្សា　　ហៅធ្ងន់មួយសារលើសលែងក្រៃ ។
ព្រះបន្ទូលព្រះពុទ្ធវិសេសលន់　　ធ្ងន់ក្រៃលែងធ្ងន់ជុតនិស្ស័យ
ព្រោះជាកំពូលលើគពៃត្រ　　រកអ្វីមកថ្លឹងផ្ទឹមពុំបាន ។

(១០) កាយស្ស ទក្ខិណោ ហត្ថា ទាសោ ឯត្ថ កនិដ្ឋកា
កណ្ណាតាសាន់មក្ខនំ វាមហត្ថោ បាទទាសោ ។

ដៃស្តាំជាខ្ញុំកាយ　　ព្រោះខ្វល់ខ្វាយរវះខ្វារខ្វាំ
កូនដៃនៃដៃស្តាំ　　ខ្ញុំត្រចៀកច្រមុះភ្នែក ។
ដៃឆ្វេងជាខ្ញុំជើង　　តាមចំរើនជើងរលក
ប្រើលាងសំពួចនៀក　　វេណីវែកតាំទុកហោង ។

(១១) គោណា ហិ សត្តគិហានំ បោសិតា ភោគទាយកា

តស្មា ហិ មាតាបិតារោ មានយេ សក្ករេយ្យ ច ។

គោរពាំងឡាយគឺជនត្រូវគេក្រាប   អាចឲ្យនូវគោរពប្រយោជន៍ផង
ដល់ត្រូវហស្ដម្ចាស់គោអ្នកគ្រប់ត្រង   ហេតុនោះហោងគួរគប់ការគោរពៗ
មើលថែទាំចិញ្ចឹមដោយទឹកស្មោ   កុំប្រែក្លាដោយចិត្តឥតមេត្តា
ប្រតិបត្តិដូចមាតានិងបិតា   ទើបចំរើនសោភាបរិបូណ៌ហោង ៗ

(១២)បជេ កុលអត្តំ ឯកំ បជេ កុលំ គាមអត្តំ
គាមជនបទអត្តំ អត្តត្តំ បឋវីំ បជេ ។

គួរលះមនុស្សម្នាក់ពេលកុំបូល   បើប្រយោជន៍ត្រកូលជួយទំនុក
គួរលះត្រកូលតាំងជាមុខ   បើប្រយោជន៍ដល់ស្រុកជាប្រធានៗ
គួរលះស្រុកទេសតាមកំណត់   បើប្រយោជន៍ជនបទប្រាកដបាន
គួរលះប្រឹថពីទីភូមិស្ថាន   បើប្រយោជន៍ដល់ប្រាណរក្សាឯងៗ

(១៣)ទេសំ ឱស្សជ្ជ គច្ឆន្តិ សីហោ សប្បុរិសោ គជោ
តត្ថេវ និធនំ យន្តិ កាកោ កាបុរិសោ មិគោ ។

រាជសីហដំរីសប្បុរសផង   ប្រទេសនៅហ្មងនាំអត្តពាយ

សឹងលះបោលទីនោះទៅមិនស្តាយ ស្វែងរកទីសប្បាយចំរើនប្រាណ ។

(១៤)ចរត្យេកេន បាទេន តិដ្ឋត្យេកេន បណ្ឌិតោ
អនីសម្ម បរំ ឋានំ ន បុព្វមាលយំ ជហា ។

បណ្ឌិតចរទៅដោយជើងម្ខាង សំអាងឈរដោយជើង១ទៀត
មិនបានត្រិះរិះនូវទីថ្មី មិនគប្បីលះបោលលំនៅចាស់ ។
(រឺ) បណ្ឌិតត្រូវចរទៅដោយចិត្ត តាំងពិនិត្យបែរមើលនូវទីថ្មី
ប្រៀបដូចឈានជើងម្ខាងទៅថ្មី កាលឈរក្តីដោយចិត្តកំពាត់ចង់ ។
លះបោលទីស្ថានចាស់មិនអាចខ្វាង ប្រៀបដូចឈរជើងម្ខាងរាំងអង្គ
មិនពិចារណាទីថ្មីរំពៃក្រន់ មិនលះបង់ទីស្ថានបុរាណចាស់ ។

(១៥)ធនធញ្ញ បយោគេសុ តថា វិជ្ជាគមេសុ ច[1]
ទូតេសុ អបចារេសុ ចជ លជ្ជា តទា ភវេ ។

ក្នុងលោកិយប្រុសស្រីលះក្តីខ្មាស មានក្នុងកាលឱកាសប្រព្រឹត្តនៅ ៤
ក្នុងកាលលក់ទិញផ្ទូរទ្រព្យឬស្រូវ ឬក្នុងកាលដែលត្រូវរៀនវិជ្ជា ។

១- បោរាណបោត្ថកេ វិជ្ជាគមេសុតាតិ ទិស្សតិ ។

បុគ្គលិកាជាទូតនាំសារគេ បុគ្គលិកាប្រែកប្រែសកាមា
ទីងសេពមេថុនការលោកា ទាសយ៉ាងណាក៏កាត់អៀនអនអើយ ៗ

(១៦)បព្វេ បព្វេ កមេនុច្ឆុ វិសេសរសោ(១) អគ្គតោ
តថា សុមេត្តកោ សាធុ វិបរិតតោ ច ទុជ្ជនោ ។

ជាតិអំពៅរសផ្អែមវិសេសខ្លាំង ក្នុង១ថ្នាំងកង់ៗដោយលំដាប់
តាំងពីចុងដល់គល់រសជាតិជាប់ លោកិយជាប់តាមចិត្តចង់កោក្កា ៗ
សប្បុរសជាតិជាមិត្រប្រពៃ មានឧបមេយ្យដូចអំពៅផ្អែមពិសា
ជាតិជនទ្រុស្តមិត្រមានឧបមា ដូចអំពៅត្រូវផ្កាវិបរិតរស ៗ

(១៧)កសកោ វាណិជោ មច្ចោ សមណោ សុតសីលវា
តេសុ វិបុលជាតេសុ រដ្ឋម្បិ វិបុលំ សិយា ។

កាកគតិៈ បុគ្គលអ្នកស្រែ ជំនួញប្រែ អាមាត្យមន្ត្រី
សមណព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតគតី មានសូត្រសីលក្តី កើតវិបុលា ៗ
ជនទាំងឡាយនោះ បើមានចំពោះនៅក្នុងដែនណា ដែននោះរុងរឿង

១· គគ្គ វិសេសរសអគ្គតោតិ ទាយតិ ។

ចុំថ្ងៃមហិមា ប្រកបសុខសា ចាយបរិបូណ៌ហោង ។

(១៨) អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។

គាកគតិ: សព្វមន្តទាំងឡាយ ពុំបានស្វាធ្យាយ ជាមន្ទិលណា គ្រឹហាទីស្ថាន ពុំបានចុះស្រាហ៍ ប្រែទៀងកាលណា ជាមន្ទិលនៅ ។ សេចក្តីកំជិល កើតជាមន្ទិល ដល់ពណ៌ហ្មងសៅ សេចក្តីប្រមាទ គឺជាតិសៅថៅ ជាមន្ទិលនៅ នៃអ្នករក្សា ។

(១៩) ហីនានំ គប្បតេ វុត្តិ វីរានំ វ សន្តុកតិ
វិទត្តិ ប ហិតា ជតា បុត្តកម្មប្រជាតតិ
ន វិទត្តិ បេវ ធីរា វាយមិស្សុ សព្វេ កម្មេ
ន បេវ សិជ្ឈតិ តំ កម្មំ អផលំ ឯវ កឹ ទោសោ ។

---

សម្បត្តិហីនជនព្យាយាមហោច, មិនបានជាប្រយោជន៍យូរអង្វែង ឲ្យបានទៅជារបស់ឯង ហីនជនទឹងថ្ងៃពោលប្ចេះណា ។

បុត្តកម្មប្រពានមាន់ពីព្រៃ លាភអើយចូរឯងវិលមកក៏
ពោះហៅយ៉ាងនេះមួយពាន់គ្រា លាភាមិនវិលមកកាន់ខ្លួន ។
អ្នកប្រាជ្ញមិនពោលកម្មាសនា តាំងតែឧស្សាហ៍ព្យាយាមមួន
ថាបើកម្មនោះមិនស្រេចជួន ឥតផលទោសខ្លួននឹងមានអ្វី ។

អធិប្បាយថា៖ មនុស្សសាបសូន្យព្យាយាម ទ្រព្យសម្បត្តិដែលមាននោះក៏ឆ្ងាក់ទៅជារបស់អ្នកព្យាយាម ពោះពោលថា ‘បុត្តកម្មប្រ-ពានដូច្នេះក៏ពុំបានលាភនោះមកវិញឡើយ, ។

ជាតិអ្នកប្រាជ្ញតាំងឡាយ, លោកតាំងព្យាយាមជាមុខ, មិនពោលទន្ទេញរកការតាំងពួងឡើយ បើការនោះពុំសម្រេចក្តី ឥតផលក្តី សេចក្តីព្យាយាមនោះនឹងបានទោសទុក្ខអ្វីទេ (គឺជាគ្មានទោសឡើយ) ។

បកិណ្ណកគណា និដ្ឋិតា បកិណ្ណកកណ្ឌចប់ហោង

ក្នុងកណ្ឌនេះ មានគាថា ១៩ គាថា

## លោកនីតិ បករណំ និដ្ឋិតំ

គម្ពីរលោកនីតិ ចប់តែប៉ុណ្ណេះ

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ក្សុរុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ម៉ាន ផាន្នី**

តុលា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដាវី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្ខារ ដឺ ឡូប៉ិស និងលោកម្តាយ ឱន សៅខុន

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា**

www.elibraryofcambodia.org

មានលក់ ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់ប្រភេទនៅ "បណ្ណាគារត្រៃរតន៍"

# 136 Eo វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខៈ ០១២ ៧០៦ ៥៨១

០៩៧ ៩០៥ ០០ ៥៥

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។